លេខ ១ ខែកក្កដា ឆ្នាំ ២០០៦

**ក្នុងអត្ថបទចេញផ្សាយនេះមាន**

- ការជួញដូរពស់ទឹក
- ក្របខណ្ឌគោលនយោបាយរួមរបស់ឋបនីយជីវមណ្ឌលបឹងទន្លេសាប
- អង្គការក្រៅរដ្ឋាភិបាលនាពេលបច្ចុប្បន្ន

# ព្រឹត្តិប័ត្រ
# ឋបនីយជីវមណ្ឌលបឹងទន្លេសាប






**លេខ១ កក្កដា ឆ្នាំ២០០៦**

រូបគម្របមុខ : ភូមិបណ្តែតទឹក នៅព្រែកទាល់ បឹងទន្លេសាប
ថតដោយ : Sonja Endlweber

បោះពុម្ពដោយ លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប
ផ្ទះលេខ ៣៦៤ មហាវិថីព្រះមុនីវង្ស ភ្នំពេញ កម្ពុជា
ទូរស័ព្ទ : (៨៥៥-០២៣) ២២១០៧៩
អ៊ីមែល : secretariat@tsbr-ed.org

ឯកសារបោះពុម្ពនេះ គឺជាផ្នែកមួយនៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ក្រោមកម្ចីហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ចំពោះរាជរដ្ឋាភិបាលកម្ពុជា

រៀបរៀងដោយ លោក បណ្ឌិត នៅ បោនន៉រ និង Sonja Endlweber
បកប្រែដោយ : ពេជ្រ សុខដានី និង សាន ផល្លា
ពិនិត្យកែសំរួលដោយ : ពេជ្រ សុខដានី និង លី សុភ័ណ្ឌ
បោះពុម្ពដោយ : រោងពុម្ព គីម ឡុង
តាក់តែង និងរចនាដោយ : Karen Young
អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន

ប្រសិនបើអស់លោក លោកស្រីចង់ចូលរួមផ្សព្វផ្សាយអត្ថបទ ព្រឹត្តិការណ៍ ឬឯកសារ ឬផ្តល់យោបល់លើអត្ថបទណាមួយនោះ សូមទំនាក់ទំនងតាមទូរស័ព្ទ :
(៨៥៥-០២៣) ២២១០៧៩

## លិខិតពីអ្នករៀបរៀង



ថបនីយជីវមណ្ឌលបឹងទន្លេសាប ជាសម្បត្តិធម្មជាតិដ៏មានតំលៃបំផុតមួយរបស់ប្រទេសកម្ពុជា។ វាផ្តល់នូវសារជាតិប្រូតេអ៊ីនពីត្រី និងប្រពន្ធ័ធារាសាស្ត្រដល់ប្រជាជនមួយផ្នែកធំនៅប្រទេសកម្ពុជា ព្រមទាំងទទួលបាននូវ[illegible]ភាពចំពោះភាពសំបូរបែបនៃជីវចម្រុះនេះ។ លេខាធិការដ្ឋានត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវការសំរបសំរួល ទំនាក់ទំនង និងការផ្លាស់ប្តូរចំណេះដឹងក្នុងចំណោមអ្នកពាក់ពន្ធ័ទាំងអស់។

ព្រឹត្តិបត្រថបនីយជីវមណ្ឌលបឹងទន្លេសាប ដែលបោះពុម្ពដោយលេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប គឺជាផ្នែកមួយនៃយុទ្ធសាស្ត្ររួម ដើម្បីបង្កើនចំណេះដឹង និងការយល់ដឹងក្នុងចំណោមថ្នាក់ដឹកនាំ មន្ត្រីជំនាញ និងសាធារណៈជន អំពីភាពសំបូរបែប និងតំលៃនៃប្រពន្ធ័អេកូឡូស៊ីធម្មជាតិ ដោយផ្តល់អោយពួកគាត់នូវព័ត៌មានទូលំទូលាយ និងថ្មីៗ។ ព្រឹត្តិប័ត្របឹងទន្លេសាបនេះ គឺជាលទ្ធផលបន្ទាប់បន្សំមួយនៃផ្នែកទិន្នន័យ-ព័ត៌មានថបនីយជីវមណ្ឌលបឹងទន្លេសាប ដែលឧបត្ថម្ភដោយគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប។

ចាប់ពីព័ត៌មានពីការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្ររហូតដល់ការរីកចំរើនរបស់គំរោង និងព័ត៌មានផ្សេងៗ ដែលទទួលបានពីបណ្តាអ្នកពាក់ពន្ធ័ដែលធ្វើការងារនៅក្នុងថបនីយជីវមណ្ឌល ព្រឹត្តិបត្រមានគោលបំណងនាំមកនូវប្រធានបទដែលគួរអោយចាប់អារម្មណ៍បំផុត រឿងរ៉ាវ និងបញ្ហាសំខាន់ៗដែលបឹងទន្លេសាបជួបប្រទះ។ លើសពីនេះ ព្រឹត្តិប័ត្រនេះនឹងផ្តល់នូវរឿងខ្លីៗអំពីជីវិតរបស់ប្រជាជននៅជនបទ ដែលរស់នៅពឹងផ្អែកលើធនធានធម្មជាតិនៃបឹងទន្លេសាប។ វាគឺជាវេទិកាសំរាប់ការពិភាក្សា និងការតស៊ូមតិ តាមរយៈការចែករំលែកទស្សនៈនិងគំនូលពីបុគ្គល អ្នកវិទ្យាសាស្ត្រ និងក្រុមការងារសង្គម។ ពុំមានការសង្ស័យថា ព័ត៌មាន និងទិន្នន័យជាក់លាក់នេះជាម៉ាស៊ីនជំរុញដំណើរការវិវត្តន៍នៅគ្រប់ផ្នែកនៃសង្គមនោះឡើយ។

យើងខ្ញុំស្វាគមន៍ជានិច្ចនូវរាល់ការចែករំលែកជាអត្ថបទ របាយការណ៍ រឿងរ៉ាវផ្សេងៗដែលទាក់ទងនឹងជីវភាពរស់នៅ និងលទ្ធផលគំរោង។ យើងខ្ញុំរីករាយនឹងទទួលយកនូវរាល់អនុសាសន៍របស់លោកអ្នកទៅលើការចេញផ្សាយនេះ។

ព្រឹត្តិប័ត្រនេះមាននៅក្នុងគេហទំព័រ : www.tsbr-ed.org

យើងខ្ញុំសង្ឃឹមថា ព្រឹត្តិប័ត្រថបនីយជីវមណ្ឌលបឹងទន្លេសាបនឹងផ្តល់ទាំងព័ត៌មាន និងអ្វីដែលគួរអោយចាប់អារម្មណ៍ដល់លោកអ្នក។

ប្រសិនបើអស់លោក លោកស្រីចង់ចូលរួមក្នុងបញ្ជីអ៊ីមែល និងចង់ទទួលបានព្រឹត្តិប័ត្រជាអេឡិចត្រូនិចហ្វាល របស់លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប សូមផ្ញើ អ៊ីមែលមកកាន់ :
secretariat@tsbr-ed.org
ព្រឹត្តិប័ត្រនេះអាចទាញយកតាមវេបសាយ www.tsbr-ed.org

# TONLE SAP
## BIOSPHERE RESERVE
# BULLETIN
VOLUME 1 JULY 2006



# CONTENTS


WATER BIRD CONSERVATION .......... 2

WATER SNAKE TRADE .......... 4

PROJECTS

- » TSBR Common Policy Framework and Coordination Mechanism .......... 6
- » Tonle Sap Environmental Management Project .......... 9
- » Champions of their World .......... 10
- » Environmental Education .......... 11
- » Environmental Information Database .......... 11
- » The Community Fishery in Spien Krong Village .......... 12
- » Update from the PIU Kampong Chhnang .......... 13
- » Training for a better biodiversity management of TSBR Core Areas .......... 14
- » Supporting sustainable livelihoods in the TSBR core areas .......... 15
- » Community Theatre at the Heart of Cambodia .......... 16

NGO NEWS .......... 17

BIOSPHERE RESERVES IN VIETNAM .......... 20

PUBLICATIONS .......... 22

CALENDAR OF EVENTS .......... 23

# WATER BIRD CONSERVATION

ម.ព.ឯ.ក AIDCC
Code:
Date:
Donated by:

A success story in Prek Toal core area

There has been - and continues to be - much written about the Tonle Sap Great Lake. It began more than a decade ago with one or two articles raising people's attention of the importance of the lake. Nowadays, it's commonplace to find coverage in regional travel magazines, television/radio programs, and international newspapers.

For the most part these stories are announcing the unique features of the lake, or highlighting social and environmental challenges. What are conspicuous by their absence are stories with hard data on what has actually been achieved on the lake by the myriad of social, developmental and environmental projects. Until now.

One particular project is now able to show – using more than four years of comparable data - results worth writing about. In the Prek Toal Wildlife Sanctuary, one of the three core areas of the Tonle Sap Biosphere



Reserve and also a major Fishing Lot, Cambodia can boast South East Asia's most dramatic wildlife recovery success story.

**Table 1.** Provides just one example of why Prek Toal now has global standing in conservation.

Prek Toal also now contains South East Asia's largest colonies of seven Globally Threatened or Near Threatened large waterbirds.




A detailed monitoring program is able to confidently show upwards trends in many of these populations and downward trend in destructive activities, providing clear evidence of the success of the project over time. This monitoring is essential not just to say 'we're succeeding' but in being able to adapt management interventions to account for changes in threats and the colonies themselves.

As with most conservation success stories, the project has humble beginnings. Surveys in 1994 first identified Prek Toal as a site of importance for large waterbirds, but also warned that uncontrolled egg collection was threatening the complete extermination of these endangered species. Further visits determined that immediate action had to be taken; that a multi-year project development period would come too late. So, with small-scale support of the Wildlife Conservation Society (WCS) a handful of dedicated national and international conservationists set out to find ways to save the colonies. Five years later, Prek Toal now boasts the region's most important site for large waterbirds, with recoveries of a host of Globally Threatened species. This is even more remarkable for the fact that this is in a region where decline and extinction are the dominant trends.

Aside from the obvious success of the wildlife recoveries, there are two other reasons to take note of this project: it was and still is run on a very small budget, and it has demonstrably contributed to improving local livelihoods in Prek Toal. In 1999,

Table 1. The table shows the population increase of the Oriental Darter over four years. Prek Toal now contains the world's largest single colony of the species.

ក្រៅពីជោគជ័យខាងលើនៃការស្តារសត្វព្រៃ មានហេតុផលពីរ ផ្សេងទៀតដើម្បីសំគាល់ពីគំរោងនេះ ៖ វាបាន និងកំពុងតែដំណើរការ ក្រោមថវិកាតិចតួច និងត្រូវបានបន្តចែករំលែកដើម្បីបង្កើនជីវភាពប្រជាពលរដ្ឋនៅមូលដ្ឋាននៅព្រែកទាល់។ នៅឆ្នាំ១៩៩៩ ដោយមានកិច្ចសហប្រតិបត្តិការរវាងក្រសួងបរិស្ថាន និងឡូតិ៍នេសាទ អង្គការ WCS បានចាប់ផ្តើមធ្វើការគាំទ្រគំរោងដោយប្រើប្រាស់ថវិកាតែពីរ ទៅបីពាន់ដុល្លានៃថវិការួមរបស់វា (core funds)។ ជាមួយនឹងការតាំងចិត្តមួយដើម្បីធ្វើការងារ នៅនឹងកប្នាក់មូលដ្ឋាន និងការជឿជាក់ថា បញ្ហាក្នុងតំបន់ត្រូវការដំណោះស្រាយក្នុងមូលដ្ឋាន ពួកគេបានចាប់ផ្តើមធ្វើការងារជាមួយប្រជាជនដែលបង្កការគំរាមកំហែងដល់បន្ទាយសត្វដែលនៅសល់ ៖ សហគមន៍នេសាទ។ គុណភាពយ៉ាងប្រុងប្រយត្ន័នៃវិធីសាស្ត្រការ៉ុត (ការងារ និងការប្រមូលប្រាក់កំរៃនៅសហគមន៍) និងដំបង (ការពង្រឹងច្បាប់) ចាប់ផ្តើមផ្លាស់ប្តូរទស្សនៈរបស់ប្រជាជនទៅលើសត្វស្លាបពីជំរើសអាហារក្នុងរយៈពេលខ្លីទៅជាជំរើសមុខរបរចិញ្ចឹមជីវិតក្នុងរយៈពេលវែង។

តាមរយៈការថ្លឹងថ្លែងផ្សេងទៀត គំរោងមានឥទ្ធិពលជាវិជ្ជមានទៅលើការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជននៅក្នុងតំបន់។ ជាដំបូង យើងនឹងលើកយកការអនុត្តនៅក្នុងទ្រង់ទ្រាយតូច។ អតីតអ្នកប្រមូលពងសត្វជាង–៣០នាក់ និងគ្រួសាររបស់ពួកគេ (ច្រើនជាង ១២០នាក់) បានទទួលផលប្រយោជន៍យ៉ាងជាប់លាប់តាមរយៈការងារអចិន្ត្រៃយ៍នៅក្នុងគំរោងអភិរក្ស។ ទាំងនេះជាប្រភេទតួលេខ–ដែលជាញឹកញាប់ ត្រូវបានមើលរំលងដោយអ្នកជំនាញការអភិវឌ្ឍន៍ ដោយចាត់ទុកថាជាចំនួនតិចតួចដែលមិនចាំបាច់ និងគ្មានចេរភាព។ ទោះជាយ៉ាងណា ប្រាំឆ្នាំក្រោមខ្សែបន្ទាត់គំរោង (វែងជាងគំរោងអភិវឌ្ឍន៍ជាច្រើនទៀត) គ្រួសារទាំងនេះនៅតែត្រូវបានជួល ហើយបច្ចុប្បន្នពួកគេមានធនធាន និងសុវត្ថិភាពអាចវិនិយោគនៅក្នុងការផ្លាស់ប្តូរជំរើសមុខរបរចិញ្ចឹមជីវិតឯករាជភាពពី គំរោង អ្នកផ្តល់ប្រាក់កំចី រឺភ្នាក់ងារផ្តល់ជំនួយ។ ក្នុងលក្ខណៈទ្រង់ទ្រាយធំ ការការពារសត្វស្លាបក៏មានន័យថាជាការការពារសត្វពីការអនុវត្តន៍ខុសច្បាប់ និងគ្មានចេរភាពដូចជាការប្រមូលឈើមូល និងការអនុវត្តការនេសាទដែលមានលក្ខណៈបំផ្លិចបំផ្លាញ។ វាជាការចាប់អារម្មណ៍ដើម្បីកត់សំគាល់ថាជាងបួនឆ្នាំកន្លងមកនេះ ចំនួនអ្នកនេសាទក្នុងតំបន់ដែលចូលមកនេសាទនៅជាយព្រែកទាល់បានកើនឡើង។ ប្រហែលជាមានហេតុផលច្រើនជាងមួយសំរាប់បញ្ហានេះ មិនមែន



ជោគជ័យគំរោងធ្វើអោយកើនឡើងនូវសំនួរដែលគួរអោយចាប់អារម្មណ៍ជាច្រើន។ តើគេនិយាយអ្វីអំពីយុទ្ធសាស្ត្រនៃការគ្រប់គ្រងបឹងនាពេលបច្ចុប្បន្ន ដែលជារឿងជោគជ័យមួយស្តីពីជីវិតសត្វ (និងជារឿងមួយនៃជោគជ័យមួយចំនួននៃមុខរបរចិញ្ចឹមជីវិត) ដែលឋិតនៅឡូតិ៍នេសាទមួយ? តើការពិភាក្សាវែកញែកលើបញ្ហាឡូតិ៍នេសាទជាមួយ

**អតីតអ្នកប្រមូលពងសត្វជាង៣០នាក់ និងគ្រួសាររបស់ពួកគេ (ច្រើនជាង ១២០នាក់) បានទទួលផលប្រយោជន៍យ៉ាងជាប់លាប់តាមរយៈការងារអចិន្ត្រៃយ៍នៅក្នុងគំរោងអភិរក្ស។**

មកពីការបរាជ័យក្នុងការគ្រប់គ្រងនៅតំបន់ផ្សេងទៀតនៅលើផ្ទៃបឹងនោះទេ ប៉ុន្តែប្រសិនបើអ្នកសួរពួកគេថាហេតុអ្វីបានជាពួកគេនៅទីនេះ ពួកគេនឹងឆ្លើយថា "ពីព្រោះនៅទីនេះមានត្រីច្រើន"។ ចំនួនត្រីនៅតែរក្សាការធ្លាក់ចុះ តែបន្ទាយសត្វស្លាបទឹកបាណជួយដល់ការពងកូន និងបង្កើនជីវជាតិទឹក ក្នុងខណៈដែលវិធានការអភិរក្សសមហេតុផលជាច្រើនក៏បានការពារជំរកពងផងដែរ ហេតុដូចនេះទើបវាបង្កើតបានជាការចែកចាយដ៏មានសារៈសំខាន់ទៅដល់សេដ្ឋកិច្ចក្នុងតំបន់។

សហគមន៍នេសាទ និងតំបន់ការពារខ្វះចន្លោះចំនុចឬ? បញ្ហាទាំងបីនេះក៏មាននៅព្រែកទាល់។ ជាក់ច្បាស់ គំរោងអភិរក្ស ព្រែកទាល់លេចឡើងដើម្បីផ្តល់ដំណោះខ្លាំងក្លាមួយសំរាប់ការចរចារតាមបែបអនុវត្តរវាងដំណោះទាំងនោះទាក់ទងជាមួយឡូតិ៍នេសាទ ការអភិរក្ស និងសហគមន៍។ គំរោងស្នើថាការអភិរក្សគឺជាជំរើសនៃការអភិវឌ្ឍពិតប្រាកដមួយសំរាប់ទីតាំងខ្លះ និងដែលការអភិរក្សដែលប្រកបដោយការគិតគូរអាចនាំទៅរកជំរើសមុខរបរចិញ្ចឹមជីវិតដែលល្អ។

ព័ត៌មានបន្ថែមអំពីអង្គការ សង្គ្រោះសត្វព្រៃនៅទំព័រទី ២០

# ការជួញដូរពស់ទឹក

ការជួញដូរពស់ទឹកនៅជុំវិញបឹងទន្លេសាបកាន់តែមានសកម្មភាពច្រើនឡើងៗគួរឱ្យកត់សំគាល់ ។ កម្មវិធីត្រួតពិនិត្យដែលបានអនុវត្តកាលពីជាងពីរឆ្នាំមុន បានបង្ហាញឱ្យឃើញថាមានសត្វពស់ជាងបួនលានក្បាលត្រូវបានគេប្រមាញ់ជារៀងរាល់ឆ្នាំ នេះគឺជាការធ្វើអាជីវកម្មធំជាងគេបំផុតនៅក្នុងពិភពលោក។

BY SHARON E. BROOKS, EDWARD H. ALLISON, JOHN D. REYNOLDS, TOUCH BUNTHANG, PROKROTEY KHOY



▲ សត្វពស់កំពុងត្រូវបានគេជួញដូរ នៅខេត្តកំពង់ឆ្នាំងបែកខាងត្បូងបឹងទន្លេសាប

មានទីផ្សារផ្សេងៗគ្នាមួយចំនួនសំរាប់សត្វពស់បឹងទន្លេសាប។ ដែលគួរអោយកត់សំគាល់នោះគឺការជួញដូរនៅក្នុងតំបន់ ដែលសត្វពស់ទាំងនេះត្រូវបានគេប្រើប្រាស់ជាចំណីសត្វសំរាប់ផ្គត់ផ្គង់សត្វក្រពើនៅតាមកសិដ្ឋានចិញ្ចឹមក្រពើជាច្រើនកន្លែងនៅក្នុង និងជុំវិញបឹងទន្លេសាប។ ការកើនឡើងនូវឧស្សាហកម្មចិញ្ចឹមក្រពើដ៏លើសលប់នៅប្រទេសកម្ពុជាកើតឡើងជាងម្ភៃឆ្នាំមកហើយ (Jelden et al.2005) ដែលជាការដាក់សម្ពាធទៅលើធនធានបឹងទន្លេសាប។ កំឡុងពេលដែលត្រីនៅតែជាធនធានចំបងដែលអាចរកបាន ការជួញដូរទៅលើប្រភេទសត្វផ្សេងទៀតនៅបឹងជាពិសេសការជួញដូរសត្វពស់បានកើនឡើងគួរឱ្យចាប់អារម្មណ៍។ នៅពេលដែលធន-ធានត្រីកម្រ អ្នកនេសាទត្រីដែលកំពុងរស់នៅតាមបឹងបានផ្លាស់ប្តូរ យុទ្ធសាស្រ្តរបស់ពួកគេពីការនេសាទត្រីទៅនេសាទសត្វពស់ទឹកដោយប្រើប្រាស់សំណាញ់។ សត្វពស់៨ប្រភេទត្រូវបានគេចាប់យ៉ាងពេញទំហឹង និងជាប្រចាំដែលក្នុងនោះមាន៥ប្រភេទជាអំបូររង Homalopsinae ដែលជាអំបូរពស់ទឹករបស់អាស៊ីខាងត្បូង។ វាត្រូវបានស្វែងអោយឃើញនៅក្នុងលទ្ធផលដែលគេអាចរកទិញសត្វពស់ទឹកបានយ៉ាងច្រើននៅក្នុងទីផ្សារក្នុងតំបន់ ដែលបណ្តាលឱ្យការប្រើប្រាស់សត្វពស់មានការកើនឡើង ហើយមានចំនួនសត្វពស់ដ៏ច្រើនដែលសព្វថ្ងៃនេះកំពុងដឹកជញ្ជូនពីបឹងទន្លេសាបទៅតាមក្រុងជុំវិញប្រទេសកម្ពុជា។ ពស់ទាំងនោះបានក្លាយទៅជាអាហារញ៉ាំលេងដែលពេញនិយមដែលជាទូទៅ គេទទួលទានបានទាំងចៀន ឬអាំងហើយនឹងជាញ៉ីកញាប់ក្លែមជាមួយទឹកត្នោតជូរនៅក្នុងតំបន់។

មានទីផ្សារអន្តរជាតិសំរាប់សត្វពស់ទន្លេសាបផងដែរ (Bonheur & Lane.2002), ទាំងប្រភេទស្បែកដែលត្រូវបានប្រើជាផលិតផលថ្លៃម៉ូដ ក៏ដូចជាសត្វរស់សំរាប់ការប្រើប្រាស់របស់មនុស្សផងដែរ ដែលជាញឹកញាប់មាននៅក្នុងភោជនីយដ្ឋានថ្លៃៗ។ ទោះបីចំនួននេះនៅតិចតួចបើប្រៀបធៀបជាមួយការជួញ-ដូរក្នុងស្រុកសំរាប់ ជាអាហារក្រពើក៏ដោយ ក៏តួលេខតិចជាង៥%នៃកសិដ្ឋានឯកជនបង្ហាញថា មានផលប៉ះពាល់ទៅលើប្រភេទដែលមានតំលៃខ្ពស់។ ប្រភេទដែលកំពុងក្លាយជាគោលដៅចំបងនោះគឺ ពស់ចាន់ល្មួ (Enhydris bocourti) និងពស់កាចាន់ (Homalopsis buccata) ហើយពស់ថ្លាន់ (Python molurus) និងពស់វែក (Naja Kaouthia and N. siamensis)ក៏ត្រូវបានគេជួញដូរម្តងម្កាលផងដែរ។

ការធ្លាក់ចុះយ៉ាងខ្លាំងនៃចំនួនសត្វពស់គ្រប់ប្រភេទដ៏ច្រើនលើសលប់ដែលត្រូវគេជួញដូរត្រូវបានរាយការណ៍ដោយអ្នកប្រមាញ់ និងអ្នកជួញដូរសត្វពស់ទឹកដែលបានលើកឡើងថា សកម្មភាពទាំងនេះមិនមានចេរភាព និងអាច




តារាង១ : រដូវធ្វើជំនួញសត្វពស់អាស្រ័យលើចំនួនចូលចតនៅកំពង់ផែចុងឃ្នាសនៅខេត្តសៀមរាប

ឈានទៅរកការបាត់បង់នានាភាពរបស់សត្វពស់និងភាពសំបូរបែបនៅទន្លេសាប។ សត្វពស់មួយប្រភេទដែលរស់នៅក្នុងបឹងទន្លេសាប (ពស់ព្រលិតផ្លុង) ហើយដែលគេតែងតែចាប់ជាប្រចាំ គឺមានតែនៅតាមទន្លេ និងបឹងទន្លេសាបប៉ុណ្ណោះ (Saint Girons 1972) ហេតុដូច្នេះគឺមានការយកចិត្តទុកដាក់ និងចាប់អារម្មណ៍ទូទាំងពិភពលោក។ អាស្រ័យដោយភាពខុសគ្នានៃជីវសាស្ត្រ និងតម្លៃទៅតាមនៃប្រភេទបានធ្វើអោយពស់ខ្លះមានតំលៃទាបជាងប្រភេទផ្សេងទៀត។ ការជួញដូរពស់ចាន់ល្មម និងពស់កាចាន់ កើតឡើងទាំងសំរាប់ជាចំណីក្រពើ និងទាំងសំរាប់ការជួញដូរស្បែក និងពស់រស់ ដែលក្នុងនោះពស់ញីជាច្រើនត្រូវបានគេស្វែងរកដើម្បីបំពេញតំរូវការទាំងនេះ។ ជាអកុសលសត្វញីទាំងនោះក៏មានសារៈសំខាន់សំរាប់បន្តពូជ ឬបង្កើតចំនួនរបស់វាថែមទៀតដែរ។ ការរួមផ្សំសម្ពាធនៃអាជីវកម្មនេះបង្កឡើងនូវផលវិបាកចំពោះពស់ពីរប្រភេទនេះ ដែលមតិនេះត្រូវបានលើកឡើងដោយដោយអ្នកស្រុកនៅក្នុងតំបន់ថាមានការថយចុះស្ទើរតែគ្រប់ប្រភេទពស់ទឹក។ ជាពិសេសពស់ចាន់ល្មមដែលមានតំលៃសំរាប់សាច់ និងស្បែក (Stuart et al 2000) ដែលឥឡូវនេះកម្រមាននៅក្នុងបឹង។

ប្រជាជនដែលកំពុងរស់នៅតាមសហគមន៍បណ្តែតទឹក បានបង្កើនប្រភពចំណូលដោយការចាប់សត្វពស់ដូចដែលបានរៀបរាប់ខាងលើហើយដែលធ្វើអោយការនេសាទត្រីមានការថយចុះ។ មនុស្សរាប់ពាន់នាក់បានចូលរួមក្នុងការប្រមាញ់សត្វពស់ ដែលមួយចំនួនចាត់ទុកទង្វើនេះជាផ្នែកមួយសំខាន់សំរាប់ជីវភាពរស់នៅរបស់ពួកគេ។ លទ្ធភាពដើម្បីធ្វើការការពារពពួកសត្វពស់ទាំងនោះ ចាំបាច់ត្រូវតែស្វែងយល់អំពីស្ថានភាពក្រីក្ររបស់ប្រជាជនកម្ពុជាផងដែរ។ ខែពិតប្រាកដដែលគេចាប់ពស់សំរាប់ផ្គត់ផ្គង់ដល់ឧស្សាហកម្មចិញ្ចឹមក្រពើនោះ គឺមានខែ មិថុនា និងខែកញ្ញា ជាខែដែលអាចរកប្រាក់ចំណូលបានច្រើនបំផុតសំរាប់ប្រជាជនទាំងនេះ។ យ៉ាងណាក៏ដោយការចាប់ សត្វពស់ធំៗសំរាប់ធ្វើការជួញដូរស្បែក និងសត្វរស់ គឺផ្តល់ផលច្រើនជាងគេ។ ដោយមានភាពលំបាក ក្នុងការស្វែងរកប្រភេទសត្វពស់ដែលមានតំលៃខ្ពស់ខណៈ



*▲ ការផ្តល់សត្វពស់ទឹកនៅទន្លេសាបធ្វើជាចំណីក្រពើ ក្រពើត្រីដែលចិញ្ចឹមដោយអោយពពួកសត្វពស់ទឹកបឹងទន្លេសាបជាចំណី (ពស់ព្រលិតផ្លុង Enhydris longicauda).*

ពេលដែលពួកវាកាន់តែខ្សត់ទៅៗ សកម្មភាពនេះ គឺមិនអាចពឹងពាក់បានទេ ដូច្នេះប្រភពនៃការស្វែងរកប្រាក់ចំណូលក៏មានកាន់តែតិចដែរ។ តម្លៃនៃការចូលរួមជាមួយសកម្មភាពនេះក៏ទាបដែរខណៈពេលដែលវាត្រូវបានគេអនុវត្តពេលស្របគ្នាជាមួយនឹងសកម្មភាពនេសាទផ្សេងទៀត ហេតុដូច្នេះ ពេលដែលតំលៃឡើងខ្ពស់ គឺដូចជាការលើកទឹកចិត្តសំរាប់បន្តការប្រមាញ់ទៀត។

សត្វពស់នៅទន្លេសាបស្តែងចេញជាផ្នែកមួយយ៉ាងសំខាន់នៃប្រព័ន្ធអេកូឡូស៊ី ដោយផ្តល់នូវអាហារសំរាប់បក្សីទឹក (Tingay & Nicoll 2006) និងសំរាប់ពពួកសត្វស៊ីសាច់ជាអាហារដោយរួមទាំងក្រពើផងដែរ (Daltry et al . 2003)។ យោងតាមចំនួនសត្វដ៏ច្រើននៅតាមដងទន្លេសាប សត្វពស់ជាច្រើនរស់នៅក្នុងព្រៃជុំវិញបឹង។ ទោះជាយ៉ាងណាក៏ជំរករបស់វាស្ថិតនៅក្រោមការគំរាមកំហែងពីការបង្វែរដីព្រៃដើម្បីធ្វើកសិកម្ម និងភ្លើងឆេះព្រៃនៅរដូវប្រាំង (Bonheur & Lane 2002) ហើយសត្វពស់នោះក៏ទទួលរងនូវសម្ពាធបន្ថែមទៀតពីការអនុវត្តន៍ខុសច្បាប់នៅតាមវាលទំនាបតាមវាលទំនាប ដូចជា ភ្ជួរ និងការបូមស្រះ និងការឆក់ត្រី។ ការការពារសហគមន៍ដែលទទួលរងការគំរាមកំហែងទៅដល់ពពួកសត្វពស់ តម្រូវឱ្យមានវិធីច្រើនដើម្បីលុបបំបាត់ការគំរាមកំហែងដែលកំពុងប្រឈមមុខនេះ។ ការការពារព្រៃលិចទឹក និងការទប់ស្កាត់អំពើខុសច្បាប់ ព្រមទាំងការបំផ្លិចបំផ្លាញ គួរតែផ្តោតលើ កិច្ចការពារជំរករបស់វា។ ការប្រមូលផលអាចធ្វើទៅប្រកបដោយចេរភាពតាមរយៈការកំនត់មួយចំនួនដូចជា បិទរដូវប្រមាញ់ដើម្បីការពារពេលរដូវបង្កាត់ពូជរបស់សត្វពស់ ហើយពង្រឹងការអនុវត្តច្បាប់ឱ្យកាន់តែខ្លាំងឡើងដើម្បីការពារការចាប់ និងលក់របស់ឯកជនធំ។

## ឯកសារយោង


Bonheur, N., and B. D. Lane. 2002. Natural resources management for human security in Cambodia's Tonle Sap Biosphere Reserve. Environmental Science and Policy 5:33-41.

Daltry, J., D. Chheang, P. Em, M. Poueng, H. Sam, P. Sorn, T. Tan, and B. K. Simpson. 2003. Status of the Siamese Crocodile in the Central Cardamom Mountains, Southwest Cambodia. FFI International Cambodia Program and Department of Forestry and Wildlife, Phnom Penh.

Jelden, D., C. Manolis, C. H. Giam, J. Thomson, and A. Lopez. 2005. Summary report of the IUCN-SSC Crocodile Specialist Group Review Mission to Cambodia. IUCN-SSC.

Saint Girons, H. 1972. Les Serpents du Cambodge. Page 170pp. Mémoires du Muséum National d'Histiore Naturelle, Paris, France.

Stuart, B. L., J. Smith, K. Davey, P. Din, and S. G. Platt. 2000. Homalopsine Watersnakes; The Harvest and Trade from Tonle Sap, Cambodia. TRAFFIC 18:115-124.

Tingay, R. E., and M. A. C. Nicoll. 2006. Asian Fishing Eagle Project: 2005 Pilot Study Report. Unpublished Report. Natural Research, Banchory, Scotland.



## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមចែករំលែកការងារនេះ ជាពិសេសសមាជិកក្រុមស្រាវជ្រាវ ដែលមានឈ្មោះ ជ័យ សែម. វណ្ណ សំបូរ. ក្រាញ់ វាសនា. ស៊ី ពេជ្យ. ឡាយ ឡេង. វណ្ណី និង ជា ចាន់បូរ៉ា ដែលបានប្រឹងប្រែង និងលះបង់ដើម្បីការងារជោគជ័យនៃគំរោង។ យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ WCS កម្ពុជា ( ហេង សុវណ្ណារ៉ា . ឡុង ឆេង. ស៊ិន វិសាល. និង ចូ វ៉ាល ស្តុន "Joe Walston" និង មជ្ឈមណ្ឌល សំ វាសនា សំរាប់អភិរក្សសត្វព្រៃ (Kristin Davies, Frederic Goes & York Pathomrath) សំរាប់ការជួយឧបត្ថម្ភក្នុងឆមា។

# គំរោងនានា

សកម្មភាពគ្រប់គ្រងធនធានធម្មជាតិជាច្រើនត្រូវបានអនុវត្តនៅតំបន់បឹងទន្លេសាប ។ ផ្នែកនេះផ្តល់នូវព័ត៌មានពីអ្វីដែលកំពុងដំណើរការនៅជុំវិញបឹងទន្លេសាប ដោយផ្តោតជាដំបូងទៅលើបញ្ហាក្របខណ្ឌគោលនយោបាយរួម ការអប់រំបរិស្ថាន និងសហគមន៍នេសាទ ។

## ›› ក្របខណ្ឌគោលនយោបាយរួម និងយន្តការសំរបសំរួលនៃជីវបម្រុងបឹងទន្លេសាប

ដោយលោក ធីមូធី វ៉ាយធីងតុន និង លោក អាំ នរិទ្ធ

គោលនយោបាយរួមដែលស្នើឡើងដោយលេខាធិការដ្ឋានជីវបម្រុងបឹងទន្លេសាប (TSBRS) បានផ្តល់ជាមូលដ្ឋានគ្រឹះសំរាប់ការបញ្ចូលផ្នែកផ្សេងៗនៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (TSEMP) និងវិធីសាស្ត្រដែលផ្អែកលើមតិរួម ដើម្បីឆ្ពោះទៅកាន់ការគ្រប់គ្រងធនធានបឹងទន្លេសាប។ គោលនយោបាយរួមទាំងនេះ (លក្ខណៈរួមក្នុងន័យចែករំលែកជារួម ដោយអ្នកពាក់ព័ន្ធនានា) មានភាពខុសគ្នារវាងគ្នានិងគ្នានៅក្នុងអ្វីដែលត្រូវបានរំពឹងទុកពីសំណាក់ស្ថាប័នរដ្ឋាភិបាល និងសង្គមស៊ីវិល។ គោលនយោបាយនីមួយៗអាចជាការឆ្លើយតបពីនាយកដ្ឋានជលផល ឬ ក្រសួងបរិស្ថាន (ស្ថាប័នសំខាន់ពីរដែលគោលនយោបាយនេះបានកំណត់យក) យ៉ាងណាក៏ដោយ ស្ថាប័នផ្សេងទៀតរបស់រដ្ឋាភិបាលអាចមានឥទ្ធិពលបន្ទាប់បន្សំប៉ុណ្ណោះ។ ជាទូទៅ នាយកដ្ឋានដែលស្ថិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងជាច្រើនទៀត (ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃជាឧទាហរណ៍) នឹងត្រូវធ្វើ ការសំរបសំរួលលើគោលបំណងនៃវិស័យរៀងៗខ្លួន ហើយនឹងទទួលបានមកវិញនូវផលប្រយោជន៍ឆ្លើយតបនឹងគោលនយោបាយរួមនេះ។ ការចូលរួមយ៉ាងសកម្មរបស់អាជ្ញាធរខេត្ត ដែលមានដូចជា ប្រធានគ្រប់គ្រងធនធានដែលមានស្រាប់ និងសមភាគីរដ្ឋាភិបាលថ្នាក់កណ្តាលគឺសំខាន់ណាស់។ ជាមួយនឹងការគ្រប់គ្រងតាមបែបវិមជ្ឈការ អាជ្ញាធរស្រុក និងក្រុមប្រឹក្សាឃុំ ក៏ដើរតួនាទីសំខាន់ផងដែរ។ ជាក់ស្តែងបែបបទដែលមានភាពស្មុគស្មាញមួយនៃការសំរបសំរួល និងផលប្រយោជន៍ នឹងចាំបាច់ត្រូវធ្វើការស្វែងយល់នៅក្នុងការអនុវត្តន៍ក្នុងរយៈពេលយូរ។

**គោលនយោបាយរួមទាំង ៣៤ កំពុងបង្ហាញពីបញ្ហានៃការគ្រប់គ្រងធនធានជាមួយគោលដៅសំខាន់នៃការគ្រប់គ្រងធនធានទន្លេសាបប្រកបដោយចីរភាព ។**

### តួនាទីរបស់លេខាធិការដ្ឋានជីវបម្រុងបឹងទន្លេសាប

លេខាធិការដ្ឋានជីវបម្រុងបឹងទន្លេសាប ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ មានតួនាទីជួយដល់ការសំរបសំរួលនៅក្នុងដំណើរការដឹកនាំ ឬការធ្វើសម្បទាន និងការបែងចែកផលប្រយោជន៍ទៅវិញទៅមក។ គោលនយោបាយរួមដែលស្នើឡើងដោយលេខាធិការដ្ឋាន ដើម្បីអនុវត្តទៅលើជីវបម្រុងបឹងទន្លេសាប ហើយដែលមិនមែនជាគោលនយោបាយរបស់លេខាធិការដ្ឋាននៅក្នុងរូបភាពណាមួយដែលក្នុងនោះលេខាធិការដ្ឋានគឺជាអ្នកពាក់ព័ន្ធមួយដែលមានតួនាទីតែមួយគត់ ក្នុងការសំរបសំរួលអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងលេខាធិការដ្ឋានជីវបម្រុងបឹងទន្លេសាប។ គោលនយោបាយរួមដែលបានស្នើឡើង នៅមិនទាន់ទទួលយកបាននៅឡើយទេ ដោយហេតុថា មានគោលនយោបាយតែចំនួនតិចតួចប៉ុណ្ណោះដែលត្រូវបានយកមកអនុវត្តជាក់ស្តែង ហើយដែលក្នុងស្ថានភាពបច្ចុប្បន្ននៃគោលនយោបាយទាំងនោះផ្តល់ជាវេទិកាសំរាប់ការកសាងការធ្វើសេចក្តីសំរេចចិត្តរួម។ សមាសភាគគោលនយោបាយរបស់គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបក៏បានស្នើឡើងពីយន្តការសំរបសំរួលមួយ និងរចនាសម្ព័ន្ធ អន្តរស្ថាប័នដែលតាមរយៈនោះគោលនយោបាយរួមអាចយកមកពិភាក្សាកែញែក និងអនុវត្តទៅតាមដំណាក់កាលដែលបានរៀបចំទុក។



◄ *ប្រធានឃុំកំពង់គោ នៅខេត្តកំពង់ធំកំពុងធ្វើកិច្ចស្វាគមន៍ក្រុមបណ្តាញការងារ គោលនយោបាយ និងយុទ្ធសាស្ត្រនៃលេខាធិការដ្ឋានជីវបម្រុងបឹងទន្លេសាប។*



▲ ប្រព័ន្ធធារាសាស្ត្រនៅក្នុងខេត្តកំពង់ធំបាននាំទៅរកការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៅក្នុងការប្រើប្រាស់ដី ការប្រែក្លាយវាលស្មៅ និងព្រៃកុម្ពោតទៅជាវាលស្រែប្រាំង ដីរកសត្វព្រៃត្រូវបានគេសំគាល់ឃើញថាត្រូវបានកាត់បន្ថយ។

**ការកើនឡើងនៃការធ្វើស្រែប្រាំងបាននាំទៅរកការបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងនៃវាលស្មៅ និងព្រៃកុម្ពោតនៅក្នុងអន្តរតំបន់ក្នុងខេត្តកំពង់ធំ**

## សំណើគោលនយោបាយរួម

ពង្រាងក្របខណ្ឌគោលនយោបាយរួមនៃបម្រុងជីវមណ្ឌលបឹងទន្លេសាប និងយន្តការសម្របសម្រួលអាចរកបាននៅគេហទំព័ររបស់លេខាធិការដ្ឋាន(www.tsbr-ed.org)។មានគោលនយោបាយរួមចំនួន ៣៤ បង្ហាញពីបញ្ហានៃការគ្រប់គ្រងធនធានជាក់លាក់ក្នុងចំណាត់ថ្នាក់បីផ្សេងគ្នា : ការអភិរក្ស ការអភិវឌ្ឍប្រកបដោយចីរភាព និងការស្រាវជ្រាវ។ ជំពូកទាំងនេះអនុលោមតាមគោលបំណងនៃបម្រុងជីវមណ្ឌលបឹងទន្លេសាបដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ។ គោលនយោបាយរួមទាំងនេះធ្វើការពង្រីកទៅដល់គោលបំណងនៃព្រះរាជក្រឹត្យដោយការស្នើឡើងពីវិធីដែលអាចធ្វើអោយធនធានជាក់លាក់នឹងត្រូវបានប្រើប្រាស់ និងថែទាំ។ ដោយសារតំរូវការចាំបាច់សំរាប់បង្ហាញពីធនធានទាំងនោះ គោលនយោបាយរួមបានធ្វើការបង្ហាញពីភាពលំអៀងនៃវិស័យមួយចំនួន តែទោះជាយ៉ាងណាគោលនយោបាយនីមួយៗ និងរាល់គោលនយោបាយទាំងអស់អាចប្រឈមមុខនឹងស្ថាប័នពីរ ឬច្រើនជាងនេះនៅក្នុងការដោះស្រាយការគ្រប់គ្រងជាអាទិភាព។ ផលប្រយោជន៍ដែលផ្តល់ឱ្យភាគី ទីបីដែលអាចមិនពាក់ព័ន្ធដោយផ្ទាល់នៅក្នុងការពិភាក្សាវែកញែកលើបញ្ហានៃការគ្រប់គ្រងធនធាន។ ផលប្រយោជន៍ជាចំបងនេះទាក់ទងនៅក្នុងការគ្រប់គ្រងប្រកបដោយចីរភាពនៅក្នុងរយៈពេលយូរនៃធនធានទន្លេសាប។

## ការចាប់ផ្តើមប្រឹងប្រែងដើម្បីឈានទៅរកគោលនយោបាយរួម

គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបបានរៀបចំវេទិកាជាច្រើនសំរាប់បង្ហាញពីក្របខណ្ឌគោលនយោបាយរួម ហើយដែលជាក់ស្តែង គោលនយោបាយរួមទាំងនេះមាននៅក្នុងការចងក្រងរបស់គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប។ ទោះយ៉ាងណាក៏ដោយមធ្យោបាយសំខាន់បំផុតសំរាប់ដោះស្រាយលើទស្សនៈនានាស្តីពីគោលនយោបាយរួម គឺនៅជុំវិញជម្លោះជាក់លាក់ទាក់ទងនឹងបញ្ហានៃការគ្រប់គ្រងធនធានដែលកំពុងកើតមានទៅលើបឹងទន្លេសាប។

គោលនយោបាយទាំងនេះត្រូវបានកំណត់ឡើងតាមរយៈការធ្វើការនៅតាមមូលដ្ឋាន និងតាមរយៈការពិភាក្សាជាមួយប្រជាជនអំពីកង្វល់នានាដែលផ្តោតលើការគ្រប់គ្រងធនធានធម្មជាតិ។ ក្រុមបណ្តាញការងារគោលនយោបាយយុទ្ធសាស្ត្របានអនុវត្តការងារស្រាវជ្រាវនៅមូលដ្ឋាននេះបានចំនួនពីរលើកមកហើយ។ ករណីទីមួយធ្វើឡើងក្នុងអំឡុងរដូវទឹកឡើងនៅខែវិច្ឆិកា ឆ្នាំ២០០៥ និងផ្តោតលើបញ្ហាដែលទាក់ទងនឹងឡូតិ៍នេសាទនៅក្នុងតំបន់ស្នូល និងធ្វើការពង្រឹងលទ្ធភាពសហ

មានតទៅទំព័រ ៨

# គំរោងនានា

គមន៍នេសាទតាមតំបន់ដីដែលមានគុណភាព។ ករណីទីពីរ ធ្វើឡើងបន្ទាប់ពីរដូវទឹកស្រក ជាពេលដែលក្រុមការងារអាចចូលទៅក្នុងអន្តរតំបន់នៅខេត្តកំពង់ធំ ពីផ្លូវជាតិលេខ៦ ដើម្បីធ្វើការវាយតំលៃបន្តទៀត លើការផ្លាស់ប្តូរយ៉ាងរហ័សនៅក្នុងការប្រើប្រាស់ដីនៅក្រោមរូបភាពនៃការធ្វើស្រែប្រាំង ដែលជាសកម្មភាពមួយដែលអាចនាំទៅកាន់ការប្រែក្លាយដីទៅជាវាលស្មៅ និងវាលព្រៃកុម្ពោត នៅក្នុងអន្តរតំបន់នៅខេត្តកំពង់ធំ។ ការងារចុះតាមមូលដ្ឋាននៅចុងក្រោយនេះ បាននាំទៅរកការចាប់ផ្តើមស្វែងយល់ពីការថ្លរនៃការប្រើប្រាស់ដីសំរាប់ការផ្គត់ផ្គង់ក្នុងតម្លៃបរិស្ថាន និងតម្លៃសហគមន៍ក្នុងចំណោមអ្នកពាក់ព័ន្ធផ្លូវការ និងក្រៅផ្លូវការជាច្រើន។ វាបង្ហាញពីវិសាលភាពជាក់ស្តែងនៃដំណើរការដែលនឹងចាំបាច់ត្រូវអនុវត្តដើម្បីធ្វើការដោះស្រាយលើសញ្ញាណ និងទស្សនវិស័យផ្សេងៗក្នុងចំណោមអ្នកពាក់ពន្ធ័។



▲ *លោក ធីមូធី វាយធីងតុន និង លោក អាំ ធរិទ្ធ កំពុងធ្វើការសំភាសន៍ប្រជាជនមកពីភូមិបណ្តែតទឹកពាមបាងនៅក្នុងខេត្តកំពង់ឆ្នាំង*

អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) បានពង្រីកការងារទៅដល់ខេត្តកំពង់ធំដើម្បីការពារជំរកសត្វខ្សឹប ដែលជាប្រភេទសត្វស្លាបដែលកំពង់រងការគំរាមកំហែង។ ការងាររបស់ពួកគេ គឺធ្វើការចងក្រងពីផលប្រយោជន៍ចម្រុះដែលសហគមន៍មូលដ្ឋានបានពីតំបន់វាលស្មៅ និងធ្វើការណែនាំថា "វិធានការបន្ទាន់ត្រូវបានអនុវត្តដើម្បីកំនត់ពីគុណភាពខ្ពស់មួយ រឺច្រើននៃវាលស្មៅក្នុងតំបន់ស្នូលដែលអាចបញ្ចូលទៅក្នុងបំបនីយជីវមណ្ឌលបឹងទន្លេសាប និងត្រូវបានការពារពីការធ្វើស្រែប្រាំង"។ តំបន់ទាំងនេះគួរត្រូវបានគ្រប់គ្រងជារួម សំរាប់ការប្រើប្រាស់នៅក្នុងសហគមន៍ ដោយរួមមានតំបន់សំរាប់ដំណាំប្រភេទស្រូវឡើងទឹកនៅរដូវដែលដីនៅទំនេរ ដោយសារវាលស្មៅគឺជាប្រភេទរុក្ខជាតិដែលកើតមានជាបន្តបន្ទាប់ ដែលផ្តល់នូវជំរកសំរាប់ប្រភេទសត្វស្លាប។ ដូចនេះ នៅក្នុងសំណើបានលើកពីជំរកជីវចម្រុះ និងគាំទ្រដល់ការប្រើប្រាស់នៅសហគមន៍ជាមួយការបង្ហាញថាសហគមន៍នឹងអនុវត្តតាមបែបកសិកម្មប្រពៃណី និងការគិតគូរពីចំណីសត្វ នៅក្នុងតំបន់ដែលត្រូវបានកំណត់។

ទស្សនៈរបស់អង្គការសមាគមអភិរក្សសត្វព្រៃបានបែងចែកទៅកាន់ទំហំធំមួយជាមួយនឹងផ្នែកនេះនៃលេខាធិការដ្ឋានដែលមានទស្សនវិស័យធំទូលាយជាង ដោយធ្វើការសង្កត់ធ្ងន់លើការប្រើប្រាស់ដីប្រកបដោយចីរភាពនៅក្នុងរូបភាពទូទៅ ដែលជាចំនុចមួយមានសារៈសំខាន់ផងដែរ។ លេខាធិការដ្ឋានបានរៀបចំសិក្ខាសាលាមួយនៅថ្នាក់ខេត្តដែលធ្វើឡើងនៅខេត្ត កំពង់ធំនៅថ្ងៃទី៧ មេសា ឆ្នាំ២០០៦ ទៅលើគោលនយោបាយរួមពាក់ពន្ធ័ដល់ការកែប្រែដីនៅក្នុងអន្តរតំបន់។ នៅក្នុងទំរង់នៃ ការអនុវត្តន៍ការអភិរក្ស លេខាធិការដ្ឋានបានធ្វើការចង្អុលបង្ហាញថាពង្រាងគោលនយោបាយរួមសំរាប់បំបនីយជីវមណ្ឌលបឹងទន្លេ សាបកំណត់ថា "ឡូតិ៍នេសាទអាចនឹង



◀ *ប្រជាជនមកពីភូមិម្យាក្រង ជុំគ្នារង់ចាំការសំភាសន៍ពីបញ្ហាប្រើប្រាស់ដី*

ត្រូវកាត់បន្ថយជាចាំបាច់ ឬ ត្រូវបានលុបចោលនៅក្នុងតំបន់ស្នូល" "ព្រំប្រទល់នឹងត្រូវធ្វើការកំណត់ទុកសំរាប់ ផែនជំរកត្រីនៅក្នុងឋបនីយជីវមណ្ឌលបឹងទន្លេសាប" កិច្ចព្រមព្រៀងនៃការបែងចែកតំបន់...សំរាប់តំបន់ការពារ និងផែនជំរកត្រី...នឹងត្រូវបានពង្រឹងដោយក្រុមប្រឹក្សាឃុំ និងអាជ្ញាធរខេត្ត" ហើយលេខាធិការដ្ឋានបានធ្វើការគាំទ្រលើ "ការការពារព្រៃលិចទឹកតាមរយៈការកំណត់តំបន់ និងគោលនយោបាយប្រើប្រាស់ដី"។

ទាក់ទងនឹងការយកចិត្តទុកដាក់លើការអភិវឌ្ឍន៍ប្រកបដោយចេរភាព ពង្រាងគោលនយោបាយរួមបានធ្វើការអះអាងថា "សម្បទានដីសង្គម នឹងត្រូវបានប្រើប្រាស់ដើម្បីផ្តត់ផ្គង់ដល់អ្នកពាក់ព័ន្ធដែលជួបការលំបាក និងក្រុមដែលងាយរងគ្រោះ" "ការអភិវឌ្ឍន៍ឯកជន...នឹង បញ្ជៀសបាននូវការប៉ះពាល់បរិស្ថានសំខាន់ៗ និងផ្តល់នូវផលប្រយោជន៍ជាអតិបរិមាដល់សហគមន៍មូលដ្ឋាន" និង "ការប្រើប្រាស់ដី និងផែនការបែងចែកធនធាននៅតាមព្រំប្រទល់ឃុំនឹងត្រូវបានរៀបចំ"។ ទស្សនៈដែលត្រូវបានផ្តល់នៅទីនេះ គឺជាវិធីសាស្ត្រត្រឹមត្រូវ ដែលគួរយកមកអនុវត្តតាម និងធ្វើការប្រើប្រាស់ទុកជាឧបករណ៍ដើម្បីគាំទ្រដល់ការគ្រប់គ្រងល្អ ដែលបានលើកឡើងនៅទីនេះថា "ទំនាក់ទំនងជាចំហ និងច្បាស់លាស់ និងព្រមព្រៀងទាំងសងខាងត្រូវបានចាត់ទុកថាជាមធ្យោបាយសំរាប់ការប្រើប្រាស់ធនធានដលត្រូវបានរឹតឹងទុកដើម្បីទាក់ទាញប្រជាជនទូទៅនៅក្នុងការធ្វើការសំរេចចិត្ត និងធ្វើសកម្មភាព"។

សិក្ខាសាលាត្រូវបានចូលរួមដោយមន្ត្រីថ្នាក់ខេត្ត និងអ្នកពាក់ព័ន្ធឯកជន រួមទាំងអ្នកអភិវឌ្ឍន៍តំបន់វាលស្រែប្រាំង។ មន្ត្រីនាយកដ្ឋានជលផលបានលើកឡើងពីការគំរាមកំហែងលើជំរកត្រីពងកូន ហើយនាយកដ្ឋានធនធានទឹក និងឧតុនិយមបានបង្ហាញពីការគំរាមកំហែងលើជីវចម្រុះ និងតំរូវការក្នុងការសិក្សាពីបញ្ហា។ នាយកដ្ឋានផែនការប្រើប្រាស់ដីធ្លីបានលើកពីទំនុកចិត្ត លើគណៈកម្មាធិការបែងចែកតំបន់វាលស្រែខាងក្រោម



ដើម្បីដកយកអាជ្ញាបណ្ណ័នៅពេលដែលមានការប៉ះពាល់អវិជ្ជមានដល់ បរិស្ថាន ឬពេលដែលព្រៃលិចទឹកត្រូវបានកាប់បំផ្លាញ ប៉ុន្តែប្រឆាំង នឹងការផ្លាស់ទីណាមួយទៅកាន់តំបន់អភិរក្ស។ អ្នកតំណាងរបស់គេបានធ្វើការអះអាងថាស្ថាប័នមិនបានសំរេចចិត្តអំពីការអនុញ្ញាត ឬថាតើអាជ្ញាធរផែនដីមានសិទ្ធិដើម្បីគ្រប់គ្រងដីដែលជាកម្មសិទ្ធរបស់រដ្ឋរឺទេ ប៉ុន្តែនៅក្នុងករណីខ្លះ វាមិនអាចបញ្ឈប់ការផ្តល់អាជ្ញាប័ណ្ណសំរាប់ការធ្វើស្រែប្រាំងបានឡើយ ដែលការធ្វើបែបនេះ អាចធ្វើឱ្យលើសពីសុពលអំណាចរបស់វាអជ្ញាធរ។ មានការពិភាក្សាដ៏ទូលំទូលាយលើប្រធានបទនេះ។ លេខាធិការដ្ឋានបានលើកឡើងថាគណៈកម្មាធិការបែងចែក ដែលបានលើកឡើងខាងលើត្រូវបានប្តូរទៅជាក្រុមការងារគ្រប់គ្រងថ្នាក់ខេត្ត ដែលចលនានេះនៅមិនទាន់អនុវត្តនៅឡើយ។ ប្រហែលជាក្រុមនេះបានសំរេចចិត្តមិនទទួលស្គាល់ថាការកែប្រែដីធ្វើឱ្យមានកត្តាគំរាមកំហែងដល់បរិស្ថាន និងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនមូលដ្ឋានឡើយ។

## សន្និដ្ឋាន

ពួកយើងពិតជាមិនដឹងថាតើកិច្ចខិតខំប្រឹងប្រែងនឹងឈានដល់ការផ្តល់ឱ្យតំបន់ដែលគ្រប់គ្រងដោយសហគមន៍សំរាប់ការអភិរក្សជំរកសត្វខ្សឹបបានយ៉ាងណានោះទេ ឬ ថាតើបញ្ហាធំជាងនេះនឹងត្រូវបានដោះស្រាយលើការបែងចែកដីប្រើប្រាស់សំរាប់ធានាការប្រើប្រាស់ធម្មជាតិចំរុះ និងផលប្រយោជន៍សហគមន៍បានយ៉ាងណា។ នៅក្នុងតួនាទីជាអ្នកពាក់ព័ន្ធ និងអ្នកសំរបសំរួលនៃគោលនយោបាយរួម លេខាធិការដ្ឋាននឹងបន្តអនុវត្តលើបញ្ហានេះ។ សំរាប់ដំណាក់កាលដំបូង លេខាធិការដ្ឋានបានស្វែងយល់ពីគោលបំណងរបស់គេដើម្បីកាត់បន្ថយការប្រើប្រាស់ដីនៅក្នុងឋបនីយជីវមណ្ឌលបឹងទន្លេសាបតាមរយៈការស្វែងរកបញ្ហានានាដែលកំពុងកើតឡើងនៅពេលបច្ចុប្បន្ន។ «

### ឯកសារយោង

Evans, T. et. al.; Farming and its impact on flooded grasslands around the Tonle Sap lake: A survey in the Kruos Kraom area of Kampong Thom; WCS Cambodia Program; June 2005.

ADB; LOAN 1939-CAM; Aide-Mémoire of the Loan Review Mission for the Tonle Sap Environmental Management Project; 3 May 2006.

# គំរោងនានា

## គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប

ដោយ *នៅ ពោធិរ័រ*
លេខាធិការរងអចិន្ត្រៃយ៍
លេខាធិការដ្ឋានជម្រកជីវមណ្ឌលបឹងទន្លេសាប

ដោយទទួលស្គាល់នូវតំលៃសេដ្ឋកិច្ច វប្បធម៌ និងអេកូឡូស៊ីដែលមានអត្ថប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជា និងដល់ប្រជាជននៅជនបទភាគច្រើន ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងការកើនឡើងនូវភាពក្រីក្រ ការវិចរិលនៃជីវចម្រុះ និងជំរករបស់វា និងការកើនឡើងនៃទំនាស់រវាងអ្នកប្រើប្រាស់ធនធាន រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តវិធានការកំណែទម្រង់ជាបន្តបន្ទាប់។ នៅឆ្នាំ ២០០០ ក្រឹត្យរបស់នាយករដ្ឋមន្ត្រីបានលុបចោលឡូត៍នេសាទ៥៦% ទៅឱ្យការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ ដែលត្រូវបានគេចាត់ទុកថាជាការលើកទឹកចិត្តដែលប្រសើរបំផុតដើម្បីឈានទៅដល់ការពង្រឹងសមត្ថភាពអាជ្ញាធរតាមតំបន់ និងដល់កម្មវិធីវិមជ្ឈការ។ នៅខែមេសា ២០០១ ព្រះរាជក្រឹត្យស្តីពីការបង្កើតជម្រកជីវមណ្ឌលបឹងទន្លេសាប ត្រូវបានអនុម័តបែងចែកតំបន់បឹងទន្លេសាបជា តំបន់ស្នូល តំបន់ទ្រនាប់ និងអន្តរតំបន់សំរាប់ការអភិរក្សជីវចម្រុះ ការលើកកំពស់ការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំរាប់ការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ និងការយល់ដឹងជាសាធារណៈ។ កំណែទម្រង់ផ្សេងទៀតដូចជា ការពិនិត្យឡើងវិញលើច្បាប់ជលផល ច្បាប់ដីធ្លី និងច្បាប់ទឹក ផ្តល់ឱ្យច្បាប់និងស្ថាប័នថ្មីៗ សំរបទៅនឹងនិន្នាការនាពេលបច្ចុប្បន្ននៃការគ្រប់គ្រងធនធានធម្មជាតិ។

ក្នុងការគាំទ្រផែនការកំណែទម្រង់ច្បាប់និងស្ថាប័ន និងកិច្ចខិតខំប្រឹងប្រែងដើម្បីលុបបំបាត់ភាពក្រីក្រ និងធ្វើឱ្យប្រសើរឡើងលើការគ្រប់គ្រងធានធានធម្មជាតិ គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (TSEMP) ត្រូវបានរៀបចំឡើង និងចុះហត្ថលេខាដោយរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅខែកុម្ភៈ ឆ្នាំ ២០០៣។ គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប គឺជាផ្នែកមួយនៃគំរោងផ្តួចផ្តើមបឹងទន្លេសាបដែលបានគ្រោងឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ីសំរាប់ជាទម្រង់អន្តរាគមន៍ដើម្បីដោះស្រាយនូវតំរូវការផ្នែកបរិស្ថាន និងការអភិវឌ្ឍអាងទន្លេសាប។



គោលដៅគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប គឺការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងជីវចម្រុះនៅក្នុងអាងទន្លេសាបដោយចីរភាព។ គោលបំណងរបស់វាគឺដើម្បីពង្រឹងប្រព័ន្ធ និងបង្កើតសមត្ថភាពសំរាប់កិច្ចសហការ និងការធ្វើផែនការគ្រប់គ្រងធនធានធម្មជាតិ ការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ និងការអភិរក្សជីវចម្រុះនៅជម្រកជីវមណ្ឌលបឹងទន្លេសាប (TSBR)។

ដើម្បីសំរេចបានគោលបំណងទាំងនេះ គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបមានសមាសភាគដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកបី :

១. ការពង្រឹងកិច្ចសំរបសំរួល និងការធ្វើផែនការគ្រប់គ្រងធនធានធម្មជាតិសំរាប់ជម្រកជីវមណ្ឌលបឹងទន្លេសាប

២. ការរៀបចំសហគមន៍គ្រប់គ្រងធនធានធម្មជាតិក្នុងជម្រកជីវមណ្ឌលបឹងទន្លេសាប

៣. ការកសាងសមត្ថភាពសំរាប់អភិរក្សជីវចម្រុះនៅក្នុងជម្រកជីវមណ្ឌលបឹងទន្លេសាប

គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបត្រូវបានអនុវត្តដោយស្ថាប័នបី : គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC) តាមរយៈលេខាធិការដ្ឋានជម្រកជីវមណ្ឌលបឹងទន្លេសាប ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) តាមរយៈនាយកដ្ឋានជលផល និងក្រសួងបរិស្ថាន (MoE) តាមរយៈនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ។ គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ឋិតនៅក្រោមការមើលខុសត្រូវដោយគណៈកម្មការតំរែតំរង់



ទិសគំរោង ដែលដឹកនាំដោយរដ្ឋមន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ដៃគូជាច្រើនដែលពាក់ព័ន្ធនៅក្នុងការអនុវត្តន៍មានដូចជា អង្គការ UNDP អង្គការ FAO អង្គការអភិរក្សសត្វព្រៃ (WCS) អង្គការ Live&Learn អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក (NGOs) និងអង្គការអ្នកស្ម័គ្រចិត្តបំរើការងារនៅបរទេស (VSO)។

គំរោងនេះធ្វើការងារនៅលើឋបនីយ–ជីវមណ្ឌលបឹងទន្លេសាប និងផ្នែកនៃខេត្តទាំងប្រាំដែលរួមមាន ខេត្តកំពង់ធំ សៀមរាប បាត់ដំបង ពោធិសាត់ និងកំពង់ឆ្នាំង នៅចន្លោះផ្លូវជាតិលេខ៥ និងលេខ៦។ រយៈពេលគំរោងមានប្រមាណ៥ឆ្នាំ ដោយឡែកសមាសភាគទីបីនៃគំរោងដែលត្រូវបានអនុវត្តតាមរយៈការគាំទ្រពី UNDP សំរាប់រយៈពេល៧ឆ្នាំ។ គំរោងសរុបគិតជាទឹកប្រាក់មានប្រមាណ១៨លានដុល្លាអាមេរិក ដែលចូលរួមផ្តល់ដោយ ADB (១០,៩លានដុល្លាអាមេរិក) មូលនិធិបរិស្ថានពិភពលោក (៣,២លានដុល្លាអាមេរិក) និងរាជរដ្ឋាភិបាលកម្ពុជា (៣,៩លានដុល្លាអាមេរិក)។ ទន្ទឹមនឹងនេះផ្នែក Capacity 21 មាន ៦៣០.០០០ដុល្លាអាមេរិកសំរាប់គំរោង "កសាងសមត្ថភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនៅតំបន់ទន្លេសាប"។

ផលប្រយោជន៍រំពឹងទុកនឹងសំដៅធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយសំរបសំរួល និងការធ្វើផែនការក្នុងចំណោមស្ថាប័នដៃគូ និងសង្គមស៊ីវិល បង្កើនចំណេះដឹង និងការចែកចាយព័ត៌មានតាមរយៈប្រព័ន្ធទិន្នន័យ និងគេហទំព័រឋបនីយជីវមណ្ឌលបឹងទន្លេសាប ធ្វើការផ្តល់អំណាចដល់សហគមន៍នៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងពង្រឹងសមត្ថភាពសំរាប់ការអភិរក្សជីវចម្រុះ។ ទោះជាលទ្ធផលសំខាន់ៗទាំងនេះអាចសំរេចបានដោយអាស្រ័យលើពេលវេលាអនុវត្តគំរោងក៏ដោយ ក៏កម្មវិធីរបស់ពួកគេនៅតែត្រូវបានទុកសំរាប់ធ្វើការសាកល្បង និងដាក់បញ្ចូលក្នុងការអនុវត្តន៍ជាក់ស្តែងទៅតាមពេលវេលាកំណត់របស់គំរោង។ ជាឧទាហរណ៍ គោលនយោបាយរួមសំរាប់ឋបនីយជីវមណ្ឌលបឹងទន្លេសាប មានសកម្មភាពគោលនយោបាយ ៣៤ ដោយក្នុងនោះមានចំនួនតិចតួចត្រូវបានធ្វើការសាកល្បង និងអនុវត្តក្នុងកំឡុងពេលនៃការអនុវត្តន៍គំរោង។ ករណីដូចគ្នានេះអាចមាននៅក្នុងការរៀបចំសហគមន៍នេសាទ។ ការធ្វើស្ថាប័នភាវូបនីយកម្មនៃលទ្ធផលទាំងនេះ ដែលជាការងារប្រចាំនៃស្ថាប័នទទួលបន្ទុក និងសង្គមគឺជាការចាំបាច់មួយបន្ទាប់ពីចុងបញ្ចប់នៃគំរោង និងត្រូវការដំណោះស្រាយពេញលេញពីស្ថាប័នអនុវត្ត ដៃគូគំរោង និងម្ចាស់ជំនួយ។ «

# គំរោងនានា

## ក្រុមអ្នកការពារពិភពលោក

ដោយ គ្រីក ម៉ុនហ្វូត និង
ចាន់ សុភក្រ័

ចូរនាំគ្នាគ្រប់គ្រងធនធានធម្មជាតិដ៏សំបូរបែបរបស់កម្ពុជាយើងដោយចេរភាព និងតាមរយៈការទទួលស្គាល់នូវតម្លៃបរិស្ថានគួបផ្សំនឹងការផ្តល់សិទ្ធិ និងលទ្ធភាពឱ្យពលរដ្ឋក្នុងការគ្រប់គ្រងផងដែរ។ ការគ្រប់គ្រងនេះត្រូវតែជាការគ្រប់គ្រងនាំមុខគេ... ។

ការតាំងចិត្តដោយមុតមាំនេះ បង្ហាញឱ្យឃើញភាពអង់អាចក្លាហានពីការរួបរួមគ្នាថ្មីមួយក្នុងសកម្មភាពអប់រំបរិស្ថានដែលកំពុងដំណើរការ នៅក្នុងខេត្តបាត់ដំបង ។



▲ *ក្រុមអ្នកការពារបរិស្ថានពិភាក្សាអំពីសកម្មភាពលើកកំពស់ការយល់ដឹង ដោយមានការគាំទ្រពីបុគ្គលិក "Village Support Group" (VSG) និងអង្គការអភិវឌ្ឍន៍ស្ត្រី។*

ភាពជាដៃគូ នៅក្នុងទម្រង់នៃគំរោងអប់រំបរិស្ថាន (EEP) នេះ ជាការរួមសហការរវាងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកពីរ គឺក្រុមគាំទ្រភូមិ "Village Support Group" (VSG) និងអង្គការអភិវឌ្ឍន៍ស្ត្រី (AS) ។

គំរោងមានគោលបំណងបង្កើនការយល់ដឹងអំពីប្រព័ន្ធបរិស្ថាន និងសេវាកម្ម និងកត្តាជំរុញទៅដល់ចេរភាព។

លោកគ្រីស បែឃឺ (Chis Baker) អ្នកសម្របសម្រួលគំរោងអប់រំបរិស្ថានមានប្រសាសន៍ "តាមរយៈការបញ្ជាក់ពីទំនាក់ទំនងរវាងមនុស្ស និងធម្មជាតិ ប្រជាពលរដ្ឋអាចទទួលស្គាល់ថា ការប្រតិបត្តិចំពោះបរិស្ថានមានសារៈសំខាន់ ដែលអាចបង្កើនគុណភាពជីវិត និងឱកាសក្នុងការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់ឱ្យកាន់តែប្រសើរឡើង"។

ចាប់តាំងពីខែកញ្ញា ឆ្នាំ២០០៥មក គំរោងអប់រំបរិស្ថាន បានចូលរួមក្នុងការងារសម្របសម្រួលបង្កើត និងអភិវឌ្ឍន៍សមត្ថភាពនៃកម្មវិធី៤ "ក្រុមអ្នកការពារបរិស្ថាន" នៅក្នុងខេត្តបាត់ដំបង។ ក្រុមនីមួយៗត្រូវបានបង្កើតឡើងដោយមានសមាសភាពដូចជា ព្រះសង្ឃ ក្រុមប្រឹក្សាឃុំ និងសមាជិកសហគមន៍នេសាទដែលស្ម័គ្រចិត្តធ្វើជាអ្នកការពារបរិស្ថាន តាមតំបន់របស់ពួកគេ។ អ្នកការពារបរិស្ថានទាំង៣១រូបបានចូលរួមកិច្ចប្រជុំពិភាក្សាផ្លាស់ប្តូរយោបល់ជំនាញដើម្បីបង្កើនចំណេះដឹង និងបទពិសោធន៍លើការសម្របសម្រួលផ្នែកបច្ចេកទេស និងប្រព័ន្ធបរិស្ថាន និងសេវាកម្មផ្សេងៗទៀត។

បច្ចុប្បន្នក្រុមអ្នកការពារបរិស្ថានទាំងនេះធ្វើសកម្មភាពដោយដើរតួជាបណ្តាញអប់រំបរិស្ថាន ជួយជ្រោមជ្រែងការងារគំរោងអប់រំបរិស្ថាន នៅក្នុសហគមន៍មូលដ្ឋានរបស់ខ្លួន និងផ្តល់មកវិញនូវអនុសាសន៍សំរាប់អោយការអប់រំបរិស្ថានបានល្អប្រសើរបំផុត និងស្របទៅតាមទិសដៅគំរោង។ ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០០៦មក ក្រុមការងារបានចាប់ផ្តើមបញ្ចូលសមាជិកថ្មីដើម្បីធ្វើសកម្មភាពអបរំបរិស្ថានក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួន និងខិតខំបង្កើតក្រុមសមាជិកជាច្រើនទៀតនៅ-តាមឃុំជិតខាង។

ក្រុមទាំងនេះបានបញ្ចូលវិធីសាស្រ្តក្នុងការលើកកំពស់ការយល់ដឹងតាមបែបប្រពៃណី និងដោយច្នៃប្រឌិត តាមរយៈការប្រើប្រាស់សម្ព័ន្ធសហគមន៍ និងបណ្តាញវត្តអារាមដើម្បីធ្វើផែនការ និងបែងចែកសកម្មភាព និងសម្ភារៈសិក្សា។ សម្ភារៈទាំងនេះរៀបចំឡើងដោយមានទំនាក់ទំនងជាមួយព្រឹត្តិការណ៍



សំខាន់ៗក្នុង និងក្រៅប្រទេសដូចជា ទិវាប្រឆាំងនឹងការនេសាទខុសច្បាប់ និងទិវាបរិស្ថានពិភពលោក (ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៥) ដើម្បីជំរុញការអនុវត្ត និងការយល់ដឹងនៅក្នុងសហគមន៍។

គន្លឹះនៃការទប់ស្កាត់មួយក្នុងចំណោមគន្លឹះទាំងអស់ដែលបានជួបប្រទះអំឡុងពេលដំបូង គឺ កង្វះការចូលរួម និងចំណាប់អារម្មណ៍ពីសហគមន៍ទាំងនោះ។ ដោយមានការជំរុញខ្លះៗ និងលើកទឹកចិត្តប្រជាជនតាមតំបន់ ក្រុមការពារបរិស្ថាននឹងរៀបចំសំដែងសិល្បៈ អំពីបរិស្ថានជាបន្តបន្ទាប់ ដែលនឹងត្រូវធ្វើឡើងនៅខែបន្តបន្ទាប់ខាងមុខ។

ការទទួលខុសត្រូវលើការវិវត្តនៃគំរោងកំពុងតែផ្លាស់ប្តូរទស្សនៈអ្នកស្ម័គ្រចិត្តឱ្យមានការគាំទ្រកាន់តែច្រើនឡើងៗ ពួកគេកំពុងបង្ហាញការប្តេជ្ញាចិត្តយ៉ាងពិតប្រាកដចំពោះតួនាទីថ្មីរបស់ពួកគេខ្លាំងឡើងៗ។ ទង្វើទាំងនេះជំរុញឱ្យប្រជាពលរដ្ឋកំពុងតែក្លាយទៅជាអ្នកការពារខ្លួនឯង ការពារសហគមន៍របស់ខ្លួន និងការពារពិភពលោករបស់ខ្លួន។

*« ព័ត៌មានបន្ថែមអំពីអង្គការក្រៅរដ្ឋាភិបាលទាំងនេះមាននៅទំព័រ ១៥ និង ២១*

# » ប្រព័ន្ធទិន្នន័យ-ព័ត៌មានបរិស្ថាន

## ដោយ ត្រី គីរីវ័ត្ន

លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប (ល.ថ.ជ.ទ) ត្រូវបានបង្កើតឡើងដោយមានរចនាសម្ព័ន្ធស្ថិតនៅក្រោមគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាដើម្បីដឹកនាំសំរបសំរួល និងពង្រឹងកិច្ចសហប្រតិបត្តិការនៅក្នុងចំណោមស្ថាប័នជាតិ អាជ្ញាធរដែនដី និងសង្គមស៊ីវិល ។ ដើម្បីជួយទ្រទ្រង់ដល់តួនាទីនេះ ទាមទារចាំបាច់ត្រូវឱ្យមានប្រព័ន្ធទិន្នន័យព័ត៌មានបរិស្ថានដែលអាចផ្តល់នូវសេវាកម្មរួម និងជាផ្លូវការមួយ ។




▲ The new TSBR web page: www.tsbr-ed.org

ក្នុងន័យនេះ អនុគំរោងរៀបចំប្រព័ន្ធទិន្នន័យ-ព័ត៌មានបរិស្ថាននៃថបនីយជីវមណ្ឌលបឹងទន្លេសាប (TSBR-ED) ក៏ត្រូវបានបង្កើតឡើងដែរ។ ប្រព័ន្ធទិន្នន័យនេះនឹងជួយគាំទ្រដល់ការងារសំរបសំរួលរបស់លេខាធិការដ្ឋាន ព្រមទាំងផ្តល់ នូវព័ត៌មានដែលស្ថាប័នជាដៃគូ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលត្រូវការ។

(TSBR-ED) ផ្តល់ឱកាសដល់គ្រប់អ្នកដែលពាក់ព័ន្ធនឹង ថ.ជ.ទ ទាំងអស់ដើម្បីចែករំលែក និងផ្លាស់ប្តូរទិន្នន័យតាមរយៈទម្រង់វេទិការួមមួយ ។

ក្រុមការងារ (TSBR-ED) នឹងបង្កើតវិធានជាយុទ្ធសាស្ត្រមួយសំរាប់អភិវឌ្ឍន៍ដល់ផ្នែកប្រព័ន្ធទិន្នន័យ-ព័ត៌មានបរិស្ថានដែលធានាដល់ការផ្តួចផ្តើម ការកំនត់នាទីមានដែនកំណត់ស្របទៅនឹងតំរូវការជាអាទិភាព និងលទ្ធភាពក្នុងការពង្រីកប្រព័ន្ធតួនាទីព្រមទាំងសមត្ថភាពសំរាប់រយៈពេលយូរអង្វែង ។

ក្រុមការងារនឹងជួយសំរួលក្នុងការបង្កើតយន្តការផ្លាស់ប្តូរព័ត៌មានមួយ (CHM) ដែលជួយដល់ដំណើរការចែករំលែកទិន្នន័យព័ត៌មានក្នុងចង្កោមអ្នកប្រើប្រាស់ក្នុងសហគមន៍ ។ ក្រុមការងារនឹងបង្កើតនូវយុទ្ធសាស្ត្រសំរាប់ចងក្រងទិន្នន័យទាំងបីប្រភេទ ជាតារាង ជាអត្ថបទ និងជាផែនទី ឬក្រាហ្វិក ក្រោមប្រធានបទផ្សេងៗគ្នាដូចជាអេកូឡូស៊ី ធារាសាស្ត្រ សេដ្ឋកិច្ច-សង្គម បរិស្ថាន។ល។ តាមរយៈវេទិការួមមួយ ។

ជាងនេះទៀតក្រុមការងារកំពុងបង្កើតគេហទំព័រ ថ.ជ.ទ (www.tsbr-ed.org) ដែលផ្តល់នូវលទ្ធភាពក្នុងការស្រាវជ្រាវទិន្នន័យ និងព័ត៌មានដែលរៀបចំដោយអនុគំរោងរៀបចំប្រព័ន្ធទិន្នន័យ-ព័ត៌មានបរិស្ថាន។ លើសពីនេះ ការបង្កើតបណ្ណាល័យមួយនៅក្នុងលេខាធិការដ្ឋានដើម្បីប្រមូល និងគ្រប់គ្រងសៀវភៅ ឯកសារបោះពុម្ព របាយការណ៍ ដំណើរការ-សិក្ខាសាលា និងឯកសារគំរោង ។

បច្ចុប្បន្នមាន របាយការណ៍ សៀវភៅ ឯកសារគំរោង ។ល។ ទាំងជាអេឡិចត្រូនិចហ្វាល និងជាឯកសារបោះពុម្ព ចំនួន ៥០០ ត្រូវបានរៀបចំចងក្រងជាបញ្ជី ។

សិក្ខាសាលាមួយស្តីពីការចែករំលែកទិន្នន័យជាមួយអ្នកពាក់ព័ន្ធ ត្រូវបានរៀបចំធ្វើឡើងនៅខេត្តសៀមរាប កាលពីថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦ ក្នុងនោះ អនុស្សារណៈយោគយល់គ្នាសំរាប់ជួយដល់យន្តការផ្លាស់ប្តូរទិន្នន័យព័ត៌មានរបស់ ថ.ជ.ទ ត្រូវបានលើកយកមកបង្ហាញដល់អ្នកពាក់ព័ន្ធទាំងអស់ ។ «



# ការបណ្តុះបណ្តាលសំរាប់ការងារគ្រប់គ្រងជីវចំរុះអោយកាន់តែប្រសើរឡើងនៅតំបន់ស្នូលនៃបំរុងជីវមណ្ឌលបឹងទន្លេសាប

ដោយ ជួប ប៉ារីស៍

គំរោងអភិរក្សបឹងទន្លេសាប (TSCP) ត្រូវបានបង្កើតឡើងក្នុងគោលបំណងចូលរួមទប់ស្កាត់ការបំផ្លាញធនធានធម្មជាតិដែលគំរាមកំហែងដល់ជីវចំរុះនៃបំរុងជីវមណ្ឌលបឹងទន្លេសាប។ គំរោងនេះត្រូវបានផ្តត់ផ្គង់ថវិកាដោយអង្គការ GEF តាមរយៈអង្គការUNDP និងស្ថាបន័ផ្សេងទៀតដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អង្គការសង្គ្រោះសត្វព្រៃ (WCS) និងរាជរដ្ឋាភិបាលកម្ពុជា។

គោលបំណងមួយនៃគំរោងនេះគឺ ការបង្កើនសមត្ថភាពសំរាប់ការគ្រប់គ្រងជីវចំរុះនៃបំរុងជីវមណ្ឌលបឹងទន្លេសាបអោយមានប្រសិទ្ធភាព។ ហេតុដូច្នេះ គំរោងកំពុងអនុវត្តសកម្មភាពរបស់ខ្លួនទៅលើការងារឃ្លាំមើល ការបណ្តុះបណ្តាល និង ការគ្រប់គ្រងតំបន់ស្នូលនៃបំរុងជីវមណ្ឌលបឹងទន្លេសាប។ ចំពោះការបណ្តុះបណ្តាលគឺ ផ្តោតជាសំខាន់ទៅលើការគ្រប់គ្រង តំបន់ការពារ និងការអភិរក្សជីវចំរុះនៃបឹងទន្លេសាប ព្រមទាំងសំដៅដល់ឧទ្យានុរក្សនៃតំបន់ស្នូលទាំងបី មន្ត្រីនៃក្រុមអនុវត្តគំរោង (PIUs) ក្នុងខេត្តជុំវិញបឹងទន្លេសាប។ លើសពីនេះទៀត មន្ត្រីមកពីមន្ទីរបរិស្ថានខេត្ត និងការិយាល័យផលផលខេត្ត ក្រុមប្រឹក្សាឃុំ នគបាលឃុំ កងរាជអាវុធហត្ថ និងអ្នកពាក់ពន្ធ័ផ្សេងទៀតក៏ត្រូវបានអញ្ជើញអោយចូលរួមផងដែរ។

ក្នុងកម្មវិធីបណ្តុះបណ្តាលសំរាប់ថ្នាក់ឧទ្យានុរក្ស សិក្ខាកាមប្រមាណ ៧៧ រូបត្រូវបានអញ្ជើញអោយចូលរួម វគ្គបណ្តុះបណ្តាលចំនួន ៣ សប្តាហ៍ (ចែកចេញជា៣វគ្គ ក្នុង ១វគ្គមានរយះពេល១សប្តាហ៍) ដែលត្រូវធ្វើឡើងចាប់ពីខែ មិនា ដល់ខែ ធ្នូ ២០០៦ ។

យោងតាមការប៉ាន់ប្រមាណតំរូវការវគ្គបណ្តុះបណ្តាលសំរាប់ថ្នាក់ឧទ្យានុរក្ស មានមេរៀនចំនួន៦ ដែលត្រូវធ្វើការបណ្តុះបណ្តាល (១) ចំណេះដឹងផ្នែកបរិស្ថាននិងការអភិរក្សជីវចំរុះ (២) ការសង្កេតនៅលើភូមិសាស្រ្ត (៣) ការប្រាស្រ័យទាក់ទងជាមូលដ្ឋាន និងដំណោះស្រាយទំនាស់ (៤) ទិដ្ឋភាពស្ថាប័ន និងច្បាប់ជាមូលដ្ឋាន (៥) ការយល់ដឹង និងការការពារភ្លើងព្រៃ (៦) សង្គ្រោះ បឋម។

## គោលបំណងនៃវគ្គបណ្តុះបណ្តាល

គោលបំណងរួមនៃវគ្គបណ្តុះបណ្តាលគឺ បំពាក់បំប៉នដល់ឧទ្យានុរក្សនូវចំណេះដឹងអំពីការគ្រប់គ្រងតំបន់ការពារ និងការអភិរក្សជីវចំរុះ សំរាប់បង្កើនប្រសិទ្ធិភាពនៃការអនុវត្តតួនាទី និងភារកិច្ច។ ចំណែកគោលបំណងនៃមេរៀនពីរតំបូងវិញ គឺ

- ផ្តល់នូវចំណេះដឹងផ្នែកបរិស្ថានទូទៅ និងបញ្ហារបស់វាក្នុងប្រទេសកម្ពុជា
- ពង្រឹងសមត្ថភាពឧទ្យានុរក្សអោយចេះវិភាគមូលហេតុ និងផលប៉ះពាល់ចំពោះបរិស្ថាន
- បង្កើនចំណេះដឹងបរិស្ថាន និងការអភិរក្សជីវចំរុះក្នុងតំបន់ស្នូលនៃបឹងទន្លេសាប
- ពង្រឹងសមត្ថភាពរបស់ឧទ្យានុរក្សអោយចេះការពារ និងអភិរក្សជីវចំរុះ
- ធ្វើអោយឧទ្យានុរក្សចេះអនុវត្តនូវសីលធម៌ចំពោះការងារអភិរក្សជីវចំរុះ
- ធ្វើអោយឧទ្យានុរក្សចេះអនុវត្តនូវការសង្កេតលើភូមិសាស្រ្ត ដើម្បីកំណត់តំបន់ជីវចំរុះ និងតំបន់អភិរក្ស ឬការកំណត់ព្រំប្រទល់។

វគ្គបណ្តុះបណ្តាលត្រូវបានបង្រៀនដោយមន្ត្រីនាយកដ្ឋានអប់រំ ព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាន (ក្រសួងបរិស្ថាន) ក្នុងកិច្ចសហការជាមួយគំរោងអភិរក្សបឹងទន្លេសាប។ សំភារៈសិក្សារួមមាន សៀវភៅអាន ឯកសារមេរៀន រូបភាពផ្សេងៗត្រូវបានផលិតឡើង និងបែងចែកដល់សិក្ខាកាមគ្រប់ៗរូប។

## សន្និដ្ឋាន

ទោះបីជាឧទ្យានុរក្សភាគច្រើនមានបទពិសោធន៍ក្នុងភូមិសាស្រ្តរយះពេល២-៥ឆ្នាំក៏ដោយ ប៉ុន្តែចំណេះដឹងទូទៅ និងកំរិតបច្ចេកទេសរបស់ពួកគាត់នៅមានកំរិតទាបនៅឡើយ ។ តាមរយះវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមទាំងអស់ទទួលបានកាន់តែច្បាស់នូវចំណេះដឹងអំពី បញ្ហាបរិស្ថានដែលគំរាមកំហែងដល់ជីវចំរុះនៃបំរុងជីវមណ្ឌលបឹងទន្លេសាប មូលហេតុ និងផលប៉ះពាល់ ព្រមទាំងដំណោះស្រាយ។ ពួកគាត់នឹងយល់ដឹងកាន់តែច្បាស់នូវសារៈសំខាន់នៃធនធានធម្មជាតិដែលជាមូលដ្ឋាន សំរាប់ជីវភាពរស់នៅរបស់ពួកគាត់ និងអំពីតួនាទីរបស់ពួកគាត់ក្នុងការអភិរក្សជីវចំរុះ និងការការពារបរិស្ថាន។ តាមការឆ្លើយតបរបស់សិក្ខាកាមចំពោះវគ្គបណ្តុះបណ្តាលលើពីរមេរៀនតំបូង បានបញ្ជាក់អោយឃើញថា ពួកគាត់រីករាយចំពោះឱកាសដែលបានសិក្សាផង និងផ្លាស់ប្តូរបទពិសោធន៍គ្នាផង។

# គំរោងនានា

## ព័ត៌មានថ្មីពីផ្នែកអនុវត្តន៍គំរោង (PIU) ខេត្តកំពង់ឆ្នាំង

ដោយ CHARLES GATHAGE

សហគមន៍នេសាទចំនួន ៥២ ត្រូវបានបង្កើតឡើងក្នុងខេត្តកំពង់ឆ្នាំង។

ខេត្តកំពង់ឆ្នាំងមានស្រុកចំនួន ៨ឃុំ ៦៩ និងភូមិ៥៥៧។ ប្រភពសេដ្ឋកិច្ចក្នុងខេត្តនេះបានមកពីការនេសាទ និងកសិកម្ម។ ក្រោយពីអនុញ្ញាតឱ្យមានការធ្វើសម្បទានឡូតិ៍នេសាទ ដើម្បីឱ្យសហគមន៍កាន់កាប់ មានឡូតិ៍នេសាទចំនួន៨ និងផ្នែកខ្លះនៃឡូតិ៍នេសាទចំនួន៦ទៀត ត្រូវបានអនុញ្ញាតឱ្យសហគមន៍នេសាទប្រើប្រាស់ទាំងស្រុងនៅក្នុងខេត្តកំពង់ឆ្នាំង។ តំបន់នេសាទដែលបានអនុញ្ញាតឱ្យប្រើប្រាស់មានចំនួនសរុប ១៧.១៧២ហិចតា ស្មើនឹង ២៧,៥៨%។



▲ សមាជិកសហគមន៍អ្នកនេសាទកំពុងដុតឧបករណ៍នេសាទខុសច្បាប់។

រហូតមកដល់បច្ចុប្បន្ន សហគមន៍នេសាទចំនួន៥២ ត្រូវបានបង្កើតឡើងនៅក្នុងស្រុកចំនួន៤ នៃខេត្តកំពង់ឆ្នាំង ដោយមានការចូលរួមពីឃុំចំនួន១២ និង១០៣៣៤គ្រួសារ។ សហគមន៍នេសាទចំនួន៤៧ ស្ថិតនៅក្នុងឡូតិ៍នេសាទចាស់ សហគមន៍នេសាទ៥ស្ថិតនៅតំបន់សាធារណៈ។ ការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការសហគមន៍នេសាទភាគច្រើនត្រូវបានបញ្ចប់ដោយបរិបូរណ៍។ សមាជិកនៃសហគមន៍នេសាទទាំងអស់បានបោះឆ្នោតដោយសំងាត់ដើម្បីជ្រើសគណៈកម្មាធិការរបស់ខ្លួន។ ស្ត្រីជាច្រើនត្រូវបានលើកទឹកចិត្តដើម្បីឱ្យចូលរួមបោះឆ្នោត និងធ្វើជាគណៈកម្មាធិការសហគមន៍នេសាទ។ សកម្មភាពរបស់សហគមន៍នេសាទត្រូវបានបញ្ចូលនៅក្នុងគំរោងអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ។

ដំណើការនៃការបង្កើតឱ្យមានសហគមន៍នេសាទ កំពុងតែត្រូវបានជួយឧបត្ថម្ភគាំទ្រដោយគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (TSEMP) តាមរយៈនាយកដ្ឋានជលផល។ ផ្នែកអនុវត្តន៍គំរោង (PIU) ត្រូវបានបង្កើតឡើងនៅតាមខេត្តទាំង៥នៅជុំវិញបឹងទន្លេសាបកំពុងបណ្តុះបណ្តាលសមាជិកសហគមន៍នេសាទ អំពីច្បាប់ជលផល រដ្ឋបាល ការយល់ដឹងអំពីបរិស្ថាន ក្សេត្រវិទ្យា និងព្រៃឈើ។



▲ ប្រធាន PIU កំពុងផ្តល់សំភារៈដល់គណៈកម្មាធិការសហគមន៍នេសាទបន្ទាប់ពីការបោះឆ្នោត

ការបង្កើតសហគន៍នេសាទ គឺជាកិច្ចការប្រឈមមុខមួយដែលតំរូវឱ្យមានការការចូលរួម និងសហការពីសំណាក់អ្នកពាក់ព័ន្ធនានា។

ការប្រឈមមុខធំបំផុតនៅក្នុងដំណើការបង្កើតសហគមន៍នេសាទ គឺប្រឈមមុខទៅនឹងសកម្មភាពនេសាទខុសច្បាប់ និងការប្រើប្រាស់ឧបកណ៍នេសាទខុសច្បាប់។ កង្វះខាតទិន្នន័យស្តីពីបរិមាណត្រី និងនិន្នាការនៃការប្រមូលផលត្រី ជាទូទៅប៉ះពាល់ដល់ការបង្កើតផែនការគ្រប់គ្រង។ ការកាប់ឆ្ការព្រៃធំៗ បណ្តាលឱ្យមានការបំផ្លិចបំផ្លាញព្រៃលិចទឹក

### សហគមន៍នេសាទនៅប្រទេសកម្ពុជា

កង្វះទីតាំងនេសាទសំរាប់សហគមន៍ក្នុងតំបន់ បង្កឱ្យមានទំនាស់ជាច្រើនកើតឡើងជាមួយម្ចាស់ឡូតិ៍ នេសាទ។ ស្ថានភាពនេះបានញ៉ាំងឱ្យសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើសម្បទានឡូតិ៍នេសាទ ពាក់កណ្តាលទៅអោយសហគមន៍នេសាទ នៅឆ្នាំ២០០០។

នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០៥ ព្រះរាជក្រឹត្យអំពីការបង្កើតសហគមន៍នេសាទត្រូវបានអនុម័ត។ បន្ទាប់មកអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទត្រូវបានអនុម័តនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០០៥។ ការផ្សព្វផ្សាយអនុក្រឹត្យទៅដល់សហគមន៍ត្រូវបានអនុវត្តដោយផ្នែកអនុវត្តគំរោងនៅតាមខេត្ត នៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប។

គោលបំណងរបស់សហគមន៍នេសាទ គឺត្រូវគ្រប់គ្រងធនធានធម្មជាតិនៅក្នុងតំបន់ឡូតិ៍នេសាទចាស់ៗឱ្យមានចេរភាព ដើម្បីបង្កើនជីវភាពរស់នៅរបស់សមាជិកសហគមន៍នេសាទឱ្យបានកាន់តែប្រសើរ និងដើម្បីកាត់បន្ថយភាពក្រីក្រ។

ដែលជាកន្លែងសំខាន់សំរាប់ត្រីបង្កាត់ពូជ។ ការប្រើប្រាស់ជីគីមីយ៉ាងច្រើន និងថ្នាំពុលសំលាប់សត្វល្អិតបណ្តាលឱ្យមានការបំពុលទឹក។ ឱកាសតិចតួចក្នុងការស្វែងរកទីផ្សារប៉ះពាល់ដល់ប្រាក់ចំណូលរបស់សមាជិកសហគមន៍នេសាទ។ បញ្ហាទូទៅនោះគឺការខ្វះជំនាញគ្រប់គ្រងក្នុងចំណោមសមាជិកគណៈកម្មាធិការសហគមន៍នេសាទ។

ជំហានបន្ទាប់ពីការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍មូលដ្ឋានតាមរយៈការអនុវត្តន៍តាមអនុក្រឹត្យស្តីពីសហគមន៍នេសាទ។

សហគមន៍នេសាទត្រូវគោរពតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ហើយនេះជាការងារចំបងរបស់ផ្នែកអនុវត្តន៍គំរោងដែលត្រូវជួយជ្រោមជ្រែងក្នុការងារនេះ។ ដើម្បីបំពេញតំរូវការនេះ សមាគមន៍នេសាទនីមួយៗត្រូវធ្វើពង្រាងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ការកំណត់ព្រំប្រទល់ និងគូសផែនទីដើម្បីបង្ហាញនូវយុត្តាធិការរបស់ខ្លួន។ ចាំបាច់ត្រូវធ្វើពង្រាងផែនការគ្រប់គ្រង និងតំបន់ ឬវិស័យដែលមានការព្រមព្រៀង។ នៅពេលអនុវត្តបានតាមអនុក្រឹត្យហើយសមាជិកសហគមន៍នេសាទត្រូវដាក់ពាក្យស្នើសុំទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយរាជរដ្ឋាភិបាល។

ផលប្រយោជន៍ដែលបានពីប្រតិបត្តិការលើសហគមន៍នេសាទ នឹងបង្ហាញអោយឃើញតាមរយៈការកាត់បន្ថយទំនាស់ ប៉ុន្តែ បង្កើនជំនាញគ្រប់គ្រង។ សមាជិកសមាគមន៍នេសាទនឹងមានលទ្ធភាពសរសេរសំណើ និងទទួលបានមូលនិធិពីអ្នកផ្តល់ជំនួយជាច្រើន។ គោលបំណងធំបំផុតដែលត្រូវសម្រេចនោះ គឺ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចេរភាព និងសមធម៌នៃការបែងចែកផលប្រយោជន៍ដល់សមាជិកសមាគមន៍នេសាទ ដែលនឹងកាន់តែធ្វើឱ្យជីវភាពរស់នៅ និងប្រាក់ចំណូលកាន់តែល្អប្រសើរឡើងថែមទៀត។ «

# » ការអប់រំបរិស្ថាន

## សំដៅបំរើដល់ការគ្រប់គ្រងតំបន់ដីសើម-ទន្លេសាប
## គំរោងអភិរក្សបឹងទន្លេសាប-កម្មវិធី ផ្សព្វផ្សាយ និងអប់រំបរិស្ថានដោយចុះផ្ទាល់ដល់មូលដ្ឋាន

ដោយ គួស ប៊ីកម៉ុលី

ប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទងទៅវិញទៅមក និងការពិនិត្យមើលលើកម្មវិធីនៅតាមសាលា គឺជាកត្តាសំខាន់នៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ក្រុមការងារផ្សព្វផ្សាយ និងអប់រំបរិស្ថានដោយចុះផ្ទាល់ដល់មូលដ្ឋាន (EAEO) នៃគំរោងអភិរក្សបឹងទន្លេសាប (TSCP)។ យុទ្ធសាស្ត្រត្រូវបានបង្ហាញដល់ជនគោលដៅនៃអ្នកពាក់ព័ន្ធសំខាន់ៗប្រមាណ៤០នាក់ នៅក្នុងសិក្ខាសាលាថ្នាក់ជាតិក្នុងរយៈពេល១ថ្ងៃ នៅថ្ងៃ ៣១ មិនា ឆ្នាំ ២០០៦។

គោលបំណងកម្មវិធីផ្សព្វផ្សាយ និងអប់រំបរិស្ថានដោយចុះផ្ទាល់ដល់មូលដ្ឋាននេះគឺ ដើម្បី ក. ជំរុញការគាំទ្ររយៈ ពេលវែងសំរាប់ការគ្រប់គ្រងបែបអភិរក្សតាមរយៈកម្មវិធីសាលា និង ដើម្បី ខ. ផ្តល់ការគ្រប់គ្រងបរិស្ថានជីវមណ្ឌលបឹងទន្លេសាបក្នុងរយៈពេលខ្លី ដោយធ្វើការរក្សាទំនាក់ទំនងទៅវិញទៅមករវាងសហគមន៍ និងអាជ្ញាធរគ្រប់គ្រង។ តំបន់គោលដៅសំរាប់កម្មវិធីទាំងនេះរួមមាននៅគ្រប់ស្រុកទាំងអស់ដែលយ៉ាងហោចណាស់ជាផ្នែកដែលឋិតនៅព្រំប្រទល់ខាងក្រៅនៃឋបនីយជីវមណ្ឌលបឹងទន្លេសាប។

លទ្ធផលរំពឹងទុកទាំងបីលើកម្មវិធីនៅតាមសាលាគឺឯកសារណែនាំសំរាប់គ្រូបង្រៀន និង សៀវភៅបង្ហាញពីសកម្មភាពសំរាប់សិស្សថ្នាក់ទីបី ទីបួន រហូតដល់ទីប្រាំបួន ដែលមានគ្រូ១៨០ដែលថ្មីកជាមួយវិធីសាស្ត្រ អប់រំបរិស្ថាន និងសំភារៈដែលផ្តល់អោយ ក៏ដូចជាក្រុមសកម្មជនអប់រំបរិស្ថានដែលមាននៅសាលាបង្គោលយ៉ាងហោចណាស់៦០សាលា។

ផ្នែកសំខាន់នៃកម្មវិធីគាំទ្រការគ្រប់គ្រងជាប្រព័ន្ធដែលចុះដល់មូលដ្ឋានសហគមន៍ ជាមួយគោលបំណងដើម្បីពិនិត្យមើលអោយបានច្បាស់លាស់ពីអ្វីដែលពាក់ពន្ធ័នឹងតំរូវការចាំបាច់ និងបញ្ហា។ ឧបករណ៍សំខាន់សំរាប់ការធ្វើទស្សនកិច្ចដំបូងមានបញ្ចូលការថតវីដេអូ ដែលធ្វើការបង្ហាញពីបញ្ហាទន្លេសាប និងឋបនីយជីវមណ្ឌលជាមួយនឹងកិច្ចសំភាសន៍ប្រជាជនមូលដ្ឋាន។ ទស្សនៈកិច្ចបន្ទាប់នឹងធ្វើឡើងដើម្បីបង្កើតកិច្ចពិភាក្សារវាងអជ្ញាធរគ្រប់គ្រង និងក្រុមអ្នកពាក់ពន្ធ័ ដែលវាជាដំណាក់កាលនៃការបង្ហាញគោលបំណងនៃការបង្រៀនដែលអាចធ្វើការគិតគូរឡើងវិញ សោតទស្សន៍ និងសំភារៈរៀនសូត្រផ្សេងទៀត ក៏ដូចជាសំណើសមហេតុផលសំរាប់ធ្វើការសហការ។

នៅជំហានចុងក្រោយ ការចុះដល់មូលដ្ឋាននឹងធ្វើឡើងក្នុងគោលបំណងដើម្បីចូលរួមជាមួយថ្នាក់ដឹកនាំសហគមន៍ មន្ត្រីសេវាកម្មស៊ីវិល ឧទ្យាននុរក្ស និងក្រុមប្រើប្រាស់ធនធាន ដែលរួមមាន ក. ការកំនត់ធនធានសំរាប់អភិរក្ស ខ. ការត្រួតពិនិត្យលើការគំរាមកំហែង និង គ. ការដោះស្រាយទំនាស់ដែលទាក់ទងនឹងបញ្ហាគំរាមកំហែងទាំងនេះនៅក្នុងតំបន់ជាក់លាក់។

កម្មវិធីទាំងនេះនឹងត្រូវធ្វើការកែសំរួលបន្តទៀត ហើយធ្វើការបង្ហាញលំអិតនៅខែក្រោយ។ «

# គំរោងនានា

## » ការទ្រទ្រង់ការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយចីរភាពនៅតំបន់ស្នូលបំរុងជីវមណ្ឌលបឹងទន្លេសាប

ដោយ ហួរ លីមឈុន ប៊ីត ភីទីស និង វិឆាត សលជី

ជំរកជីវមណ្ឌលបឹងទន្លេសាប (TSBR) គឺជាកន្លែងតាំងនៅរបស់មនុស្ស យ៉ាងហោចណាស់សំរាប់រយៈពេលមួយក្នុងមួយឆ្នាំ ដែលតាមការប៉ាន់ស្មានទៅមានប្រមាណ ១,៦លាននាក់។ ទាំងប្រជាជនដែលរស់នៅជាអចិន្ត្រៃយ៍នៅក្នុងភូមិបណ្តែតទឹកក្នុងតំបន់ និងប្រជាជនដែលផ្លាស់ទីតាមរដូវទឹកឡើង និងទឹកស្រកប្រចាំឆ្នាំ អាស្រ័យលើភាពសំបូរបែបនៃជីវចម្រុះសំរាប់ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ។

ជំរកជីវមណ្ឌលត្រូវបានគេបំរុងទុកជាតំបន់ដែលកំនត់ពីការអនុវត្តប្រកបដោយតុល្យភាពរវាងជំលោះលើគោលបំនងនៃការអភិវឌ្ឍធនធានមនុស្ស ដែលតែងតែកើតឡើង-ជាញឹកញាប់ និងការអភិរក្សជីវចំរុះ។ គោលបំណងទាំងនេះត្រូវបានលើកឡើងនៅក្នុងអន្តរតំបន់ (តំបន់ដែលការគ្រប់គ្រងផ្តោតលើការអភិវឌ្ឍប្រកបដោយចីរភាពដើម្បីផ្គត់ផ្គង់សហគមន៍ក្នុងតំបន់) តំបន់ទ្រនាប់ (តំបន់ដែលការប្រើប្រាស់ធនធានធម្មជាតិត្រូវបានកំណត់ដើម្បីឱ្យស្របជាមួយការអនុវត្តអេកូឡូស៊ីល្អ) និង តំបន់ស្នូល (កន្លែងដែលធ្វើការសង្កត់ធ្ងន់ទៅលើការអភិរក្សជីវចម្រុះ)។



▲ ការធ្វើត្រីប្រហុកនៅក្នុងភូមិបណ្តែតទឹក

នៅពេលដែលជំរកជីវមណ្ឌលបឹងទន្លេសាប ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០១ វាត្រូវបានគេកំនត់យ៉ាងច្បាស់ថា តំបន់ស្នូលជាដែនដីរក្សាទុកដ៏សំខាន់ និងការនេសាទក្នុងលក្ខណៈគ្រួសារក្នុងកម្រិតមធ្យម និងការនេសាទអាជីវកម្ម ត្រូវបានអនុញ្ញាតឱ្យបន្តដោយយោងលើច្បាប់ជលផលកម្ពុជា។ ទោះជាវិធានការត្រួតពិនិត្យត្រូវបានកំនត់ទៅរកការការពារធនធានដែលសំខាន់ជាងគេ រឺធនធានដែលងាយរងគ្រោះត្រូវបានបង្កើតឡើងក៏ដោយ ក៏ការប្រមូលផលផ្សេងៗនៃធនធានផ្សេងទៀត (ឧស ពស់ទឹក អណ្តើក សត្វស្លាបទឹក និងសត្វព្រៃផ្សេងៗទៀត) នៅតែបន្ត។ ផលវិបាកនេះមិនមែនជារឿងតូចតាចឡើយ ថ្មីៗនេះ ចំនួនប្រជាជនដែលរស់នៅក្នុង និងជុំវិញតំបន់ស្នូលមានចំនួន ១៨៦៩គ្រួសារនៅព្រែកទាល់ ៩៧៤គ្រួសារនៅស្ទឹងសែន និង ៦១៦គ្រួសារនៅបឹងទន្លេឆ្មារ។

ដូចដែលគេបានដឹងហើយថា តំបន់ស្នូលពោរពេញដោយធនធានអេកូឡូស៊ីមានតំលៃ ប៉ុន្តែយើងក៏ដឹងដែរថាប្រជាជននៅភូមិជុំវិញពឹងអាស្រ័យលើធនធានទាំងនេះសំរាប់ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ ហេតុនេះតើយើងត្រូវធ្វើដូចម្តេចដើម្បីឆ្ពោះទៅសំរេចបានគោលដៅទាំងពីរនៃការអភិរក្សធនធានធម្មជាតិ និងការផ្តល់ប្រយោជន៍ដល់សហគមន៍មូលដ្ឋាន? វិធីសាស្រ្តដែលអនុវត្តដោយ TSCP (គំរោងអភិរក្សបឹងទន្លេសាប) គឺដើម្បីកាត់បន្ថយសំពាធទៅលើធនធានតំបន់ស្នូលដោយលើកទឹកចិត្តដល់ការផលិតអាហារជាលក្ខណៈគ្រួសារ (ត្រី ការចិញ្ចឹមសត្វខ្នាតតូច និងការដាំបន្លែ ទាំងសំរាប់ការប្រើប្រាស់ និងសំរាប់លក់នៅក្នុងភូមិ) លើកទឹកចិត្តលើប្រសិទ្ធភាពនៃការប្រើប្រាស់អុសធ្យូង (ដោយផ្តល់នូវបច្ចេកវិទ្យាសាមញ្ញ និងមានតំលៃថោក ដូចជា ចង្ក្រានប្រសិទ្ធភាពថាមពលជាដើម) និងផ្តល់លទ្ធភាពក្នុងការទទួលបានការប្រកបរបរចិញ្ចឹមជីវិតផ្សេងៗទៀត (ឧទាហរណ៍ ការផ្តល់ទំនិញ និងសេវាកម្មសំរាប់អ្នកទេសចរធម្មជាតិ)។ ទាំងអស់នេះត្រូវបានរំពឹងទុកដើម្បីកាត់បន្ថយតំរូវការនៃការធ្វើដំណើរទៅកាន់តំបន់ស្នូលដើម្បីប្រមូលផលពីធនធានជីវចម្រុះ។

ជំហានបន្ទាប់គឺដើម្បីបង្កើតក្រុមបង្កើនជីវភាពរស់នៅ (LEG) (ប្រមាណបីក្រុមនៅក្នុងតំបន់ស្នូលព្រែកទាល់ ប្រាំក្រុមនៅស្ទឹងសែន និងប្រាំក្រុមនៅបឹងទន្លេឆ្មារ) ដែលក្រុមនីមួយៗមានសមាជិកមិនលើសពី៣០គ្រួសារ ដើម្បីបង្កើតជាសកម្មភាពគំរូនៃការប្រកបរបរចិញ្ចឹមជីវិតដែលត្រូវបានជ្រើសរើសដោយក្រុម។ តំលៃសរុបនៃសកម្មភាពគំរូ រួមមានការផ្តល់ប្រឹក្សាបច្ចេកទេស និងបំពាក់បំប៉នសមត្ថភាព នឹងត្រូវបានផ្តល់ដោយគំរោងអភិរក្សបឹងទន្លេសាប ដោយឡែក សមាជិក-សហគមន៍ត្រូវផ្តល់ជាកំលាំងពលកម្ម និងចំណេះដឹងមូលដ្ឋានដែលគាត់មាន។ ក្រុមបង្កើនជីវភាពរស់នៅ ត្រូវបានរំពឹងទុកថានឹងឈានទៅបង្កើតជាអង្គការសហគមន៍មូលដ្ឋានដើម្បីឈានទៅរកការផ្គត់ផ្គង់ដោយខ្លួនឯងលើការអនុវត្តបន្តលើសកម្មភាពគំរូណាដែលទទួលបានជោគជ័យ និងអាចទទួលយកបានសំរាប់មូលដ្ឋាន ជាមួយនឹងទិសដៅប្រមាណ ១០ភាគរយនៃចំនួនគ្រួសារទាំងអស់ដើម្បីបន្សាំជាមួយសកម្មភាពជំរើសមុខរបរនៅចុងបញ្ចប់គំរោងនៅឆ្នាំ ២០១១។

សកម្មភាពលើការប្រកបរបរចិញ្ចឹមជីវិតរបស់គំរោងអភិរក្សបឹងទន្លេសាបកំពុងត្រូវបានអភិវឌ្ឍន៍នៅក្នុងកិច្ចសំរបសំរួលជាមួយផែនការគ្រប់គ្រងរយៈពេលប្រាំឆ្នាំសំរាប់តំបន់ស្នូលនីមួយៗ ហើយនឹងត្រូវអនុវត្តនៅក្នុងកិច្ចសហការជាមួយម្ចាស់ជំនួយផ្សេងៗ អង្គការក្រៅរដ្ឋាភិបាល និងការផ្តួចផ្តើមលើការប្រកបរបរចិញ្ចឹមជីវិតដែលគាំទ្រដោយរាជរដ្ឋាភិបាល។ «

# ព័ត៌មានពីអង្គការក្រៅរដ្ឋាភិបាល

## » ជាង៣០០អង្គការក្រៅរដ្ឋាភិបាលកំពុងធ្វើការងារនៅតំបន់ទន្លេសាប

ដោយ សូញ៉ា អិនឌុលវេបឺ

នៅឆ្នាំ ២០០៥ ចំនួននៃអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការនៅក្នុងប្រទេសកម្ពុជាមានលើសពីមួយពាន់អង្គការ (៧០%ជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និង ៣០%ជាអង្គការក្រៅរដ្ឋាភិបាលក្រៅស្រុក)។ ជាមួយនឹងធនធានធម្មជាតិដ៏សំបូរបែប ឋបនីយជីវមណ្ឌល–បឹងទន្លេសាប គឺជាតំបន់ដែលអង្គការក្រៅរដ្ឋាភិបាលជាច្រើនផ្តោតការយកចិត្តទុកដាក់ធ្វើសកម្មភាពរបស់ខ្លួន។ មានអង្គការក្រៅរដ្ឋាភិបាលជាង៣០០កំពុងធ្វើការនៅក្នុងឋបនីយជីវមណ្ឌលបឹងទន្លេសាបលើវិស័យមួយចំនួន ដូចជា ការលើកកំពស់ការយល់ដឹង ការបណ្តុះបណ្តាល និងការអប់រំ ការអភិវឌ្ឍសហគមន៍ ការបង្កើតសហគមន៍នេសាទ និងសហគមន៍ព្រៃឈើ ដើម្បីអភិរក្សបរិស្ថាន ទេសចរណ៍ធម្មជាតិ សិទ្ធិមនុស្ស ប្រជាធិបតេយ្យ យេនឌ័រ និងបញ្ហាស្ត្រី។

ចំនួនអង្គការក្រៅរដ្ឋាភិបាល កំពុងមានការកើនឡើងជារៀងរាល់ឆ្នាំ។ ស្ថិតិបានបង្ហាញថាចំនួនអង្គការក្រៅរដ្ឋាភិបាលបានកើនឡើង ពី១៨០ នៅឆ្នាំ ១៩៩៤ រហូតដល់ ១០០០នៅឆ្នាំ ២០០៥ ។

មានហេតុផលមួយចំនួនដែលធ្វើឱ្យអង្គការក្រៅរដ្ឋាភិបាលផ្តោតការងារលើឋបនីយជីវមណ្ឌលបឹងទន្លេសាប។ ការការពារធនធានធម្មជាតិដ៏មានតំលៃបំផុតរបស់ប្រទេសកម្ពុជា គឺជាហេតុផលចំបងមួយ។ ប្រទេសកម្ពុជាពឹងផ្អែកលើធនធានជលផល និងធនធានមច្ឆា។ បឹងទន្លេសាប គឺជាបឹងដែលផ្តល់ផលត្រីច្រើនជាងគេមួយលើពិភពលោក និងគួរត្រូវបានបន្តផ្តល់ផលខ្ពស់ដូចនេះទៅថ្ងៃអនាគត។ លោកស្រី ឡាំ សៅឡេង ដែលជាអ្នកសំរបសំរួលកម្មវិធីបរិស្ថាននៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum ) បានពន្យល់ថា "មានតំរូវការខ្ពស់ពីសហគមន៍គាំទ្រដោយអង្គការក្រៅរដ្ឋាភិបាល ។ ពេលដែលប្រឈមមុខនឹងបញ្ហានេសាទខុសច្បាប់ រឺការនេសាទដោយប្រើឧបករណ៍ខុសច្បាប់ សហគមន៍នៅជុំវិញបឹងទន្លេសាបជាញឹកញាប់បានអំពាវនាវឱ្យអង្គការក្រៅរដ្ឋាភិបាលជួយ" ដោយសារទន្លេសាបត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជាឋបនីយជីវមណ្ឌល ដូច្នេះម្ចាស់ជំនួយអន្តរជាតិក៏មានការចាប់អារម្មណ៍ខ្លាំងផងដែរ។

អង្គការក្រៅរដ្ឋាភិបាលនៅខេត្ត៥ជុំវិញបឹងទន្លេសាបកំពុងធ្វើការសំរបសំរួលការងាររបស់ខ្លួន។ បណ្តាញការងារ រឺ C-NGO (អង្គការក្រៅរដ្ឋាភិបាលកម្ពុជា) ត្រូវបានបង្កើតឡើងនៅគ្រប់ខេត្ត។ C-NGO មានតួនាទីនាំមុខក្នុងការសំរបសំរួលគ្រប់អង្គការក្រៅរដ្ឋាភិបាលទាំងអស់នៅតាមខេត្ត និងដឹកនាំកិច្ចប្រជុំប្រចាំខែ រួមជាមួយនឹងក្រុមបណ្តាញការងាររង ត្រូវបានបង្កើតឡើងដោយផ្តោតលើប្រធានបទច្បាស់លាស់។ ជាគោលការណ៍ C-NGO មានអណត្តិដឹកនាំរយៈពេលពីរឆ្នាំ បន្ទាប់មកនឹងត្រូវផ្ទេរទៅឱ្យអង្គការក្រៅរដ្ឋាភិបាលមួយផ្សេងទៀតជាអ្នកដឹកនាំបណ្តាញនេះវិញម្តង ។ «

## » អង្គការអភិរក្សសត្វព្រៃ

អង្គការអភិរក្សសត្វព្រៃ គឺជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិសកម្មមួយដែលធ្វើការងារនៅកម្ពុជាចាប់ពីឆ្នាំ ១៩៩៩មក។ គោលបំណងនៃការអភិរក្ស គឺសំដៅសំរេចបានតាមរយៈការយកចិត្តទុកដាក់តាមលក្ខណៈ វិទ្យាសាស្ត្រ កិច្ចសហការ ការអប់រំ និងការគ្រប់គ្រងប្រព័ន្ធឧទ្យានសត្វព្រៃធំបំផុតលើពិភពលោក ដែលនាំមុខដោយសួនសត្វប្រចាំតំបន់ប្រុន (Bronx)។ ជាមួយគ្នានេះ សកម្មភាពទាំងនេះសំដៅផងដែរ ដើម្បីធ្វើការផ្លាស់ប្តូរឥរិយាបទ

បុគ្គលទៅលើធម្មជាតិ និងជួយប្រជាជនឱ្យប្រមើលមើលពីការរស់នៅរបស់សត្វព្រៃ និងមនុស្សនៅក្នុងទំនាក់ទំនង ដែលប្រកបដោយចេរភាពទាំងទៅលើមូលដ្ឋាន និងទូទាំងពិភពលោក។ WCS សំរេចតាំងចិត្ត



ទៅលើចាប់យកការងារនេះ ព្រោះជឿជាក់ថាវាមានសារៈសំខាន់សំរាប់បូរណភាពនៃជីវិតលើផែនដី។

នៅកម្ពុជា WCS ធ្វើការងារនៅក្នុងតំបន់ពាក់ខ្លែង ចាប់ពីកម្មវិធីទេសភាពទំហំធំទៅកម្មវិធីដែលផ្តួចផ្តើមដោយផ្អែកលើសហគមន៍។ ការងារនេះធ្វើឡើងតាមរយៈសកម្មភាពនៅនឹងមូលដ្ឋានដែលផ្តោតលើការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ព្រមទាំងការផលិតឯកសារបច្ចេកទេសសមស្រប និងលើកកំពស់ការយល់ដឹងជាភាសាខ្មែរ។ អង្គការ WCS នៅកម្ពុជាបច្ចុប្បន្នមានបុគ្គលិកពេញម៉ោង ១៥០នាក់នៅក្នុងខេត្តចំនួន៨។

ចូ វ៉ាល់ស្តុន នាយកកម្មវិធីប្រចាំប្រទេស
ផ្ទះលេខ ២១ ផ្លូវលេខ ២១
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
ក្រុងភ្នំពេញប្រអប់សំបុត្រ ១៦២០
ទូរស័ព្ទ ៨៥៥)១២ ៩៥៤ ២៥៧
អ៊ីម៉ែល jwalston@wcs.org
គេហទំព័រ www.wcs.org/international/Asia/Cambodia/Tonle_Sap

## » ក្រុមគាំទ្រភូមិ-VSG

VSG ត្រូវបានចុះឈ្មោះជាមួយរដ្ឋាភិបាលនៃប្រទេសកម្ពុជា និង គណកម្មាធិការសហប្រតិបត្តិការសំរាប់កម្ពុជា (CCC) នៅឆ្នាំ១៩៩៥។ ចាប់តាំងពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ១៩៩៦ VSG បានដំណើរការកម្មវិធីសុវត្ថិភាពស្បៀង និង ជំនឿនៅខេត្តបាត់ដំបង។ ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០០ បានឈានទៅដល់សមាហរណកម្មគំរោងអភិវឌ្ឍន៍សហគមន៍។ គោលបំណងគឺ "ដើម្បីផ្សព្វផ្សាយចំណេះដឹង/ជំនាញអោយបានទូលំទូលាយរួមទាំងគំនិតផ្តួចផ្តើមលើការការពារបរិស្ថាននៅថ្នាក់សហគមន៍។ បច្ចុប្បន្នសកម្មភាពរបស់អង្គការនេះរួមមាន សមាហរណកម្មគំរោងអភិវឌ្ឍសហគមន៍ (ធនាគារស្រូវ ឥណ្ឌទានស្រែប្រាំង សួនបន្លែតាមផ្ទះ និង អាហាររូបត្ថម្ភ (និងការចិញ្ចឹមគោ) និងធ្វើលើបញ្ហាជលផលដែលកំពុងកើតមានហើយ VSG បានធ្វើការជាមួយបណ្តាញការងាររបស់អង្គការក្រៅរដ្ឋាភិបាលជាពិសេសជាមួយអង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល។ នាពេលថ្មីៗនេះពួកគេផ្តោតការយកចិត្តទុកដាក់ទៅលើខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។

លោក រស់ ឆ្លួលវីវ៉ន : នាយកអង្គការ
ទូរស័ព្ទ : ០១២ ៩១៥ ៥៤០/០៥៣ ៧៣០ ៣៥៥
អ៊ីម៉ែល : vsg@online.com.kh
ផ្ទះលេខ ១៧៧ ក្រុម ២១ កំពង់ក្របី
ស្រុកស្វាយពោរ ខេត្តបាត់ដំបង



## » NGO FORUM

NGO Forum ជាសមាជិកអង្គការក្នុងស្រុក និងអង្គការក្រៅរដ្ឋាភិបាលក្រៅស្រុកដែលផ្តោតលើការចែករំលែកព័ត៌មាន កិច្ចពិភាក្សាវែកញែក និងការតស៊ូមតិលើបញ្ហាអាទិភាពដែលប៉ះពាល់ដល់ការអភិវឌ្ឍកម្ពុជា។ NGO Forum ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៥ និងប្រកាន់តួនាទីជាអ្នកដឹកនាំសំរបសំរួល និងផ្សះផ្សា។ វេទិកានេះផ្តោតលើការលើកកំពស់ការយល់ដឹង និងកសាងសមត្ថភាព។ វាជួយគាំទ្រដល់ការងារស្រាវជ្រាវ ផ្តល់ព័ត៌មានទៅកាន់អ្នកសារព័ត៌មាន និងសំរបសំរួលជាមួយអាជ្ញាធរក្នុងតំបន់។ NGO Forum សព្វថ្ងៃនេះមានសមាជិកចំនួន៧៥។

ក្រៅពីកម្មវិធីអភិវឌ្ឍន៍ និងកម្មវិធីដីធ្លី និងការប្រកបរបរចិញ្ចឹមជីវិត កម្មវិធីបរិស្ថានជាកម្មវិធីចំបងមួយក្នុងចំណោមកម្មវិធីចំបងទាំងបីរបស់ NGO Forum។ កម្មវិធីបរិស្ថាននេះជារួមមានគំរោងបន្ទាប់បន្សំចំនួនបីថិតក្រោមនេះទៀត គឺ : គំរោងការពារ និងចំណេះដឹងបរិស្ថាន គំរោងកាត់បន្ថយថ្នាំសំលាប់កត្តាចង្រៃ និងនិរន្តរភាពកសិកម្ម និងគំរោងសិទ្ធិសហគមន៍នៅអាងទន្លេមេគង្គ ។ កម្មវិធីបរិស្ថាននេះចាប់ផ្តើមនៅឆ្នាំ ១៩៩៥។

ផ្ទះលេខ ៩-១១ សង្កាត់ទួលទំពូង១ ភ្នំពេញ
ទូរសព្ទ័ ០២៣ ២១៤ ៤២៩
អ៊ីម៉ែល :ngoforum@ngoforum.org.kh
គេហទំព័រ : www.ngoforum.org.kh



## » អង្គការសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍កម្ពុជា

អង្គការសហប្រតិបត្តិការ ដើម្បីអភិវឌ្ឍន៍កម្ពុជាជាអង្គការក្រៅរដ្ឋាភិបាល មានទីតាំងនៅក្នុងខេត្តកំពង់ធំ។ បេសកកម្មរបស់អង្គការនេះ គឺពង្រឹងសមត្ថភាពជនក្រីក្រក្នុងន័យបង្កើនកំរិតស្តង់ដារនៃការរស់នៅឱ្យបានប្រសើរឡើង។ អង្គការសហប្រតិបត្តិការ ដើម្បីអភិវឌ្ឍន៍កម្ពុជា ធ្វើការងារលើកម្មវិធីមួយចំនួនដូចជាសហគមន៍នេសាទ កសិកម្ម សុខភាព វិមជ្ឈការ ក្រុមសន្សំប្រាក់ និងឥណទាន និងយេនឌ័រ។

អាសយដ្ឋានទំនាក់ទំនង :
ភូមិបាល្ល័ងលិច ឃុំដំរីជាន់ខ្លា ស្រុកស្ទឹងសែន
ខេត្តកំពង់ធំ
ទូរស័ព្ទ : ០៩២ ៩១៦០៦៥
អ៊ីម៉េល : codeckt@yahoo.com

## » អង្គការអភិវឌ្ឍន៍ស្ត្រី

អង្គការអភិវឌ្ឍន៍ស្ត្រី ជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក មានទីតាំងនៅក្នុងខេត្តបាត់ដំបង និងធ្វើការងារសំដៅផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន និងផ្តោតលើបញ្ហាអភិវឌ្ឍន៍ជនបទអស់រយៈពេលជាង ១០ឆ្នាំមកហើយ។ អង្គការនេះធ្វើការងារលើកម្មវិធីចំនួន៤ គឺ : ការគ្រប់គ្រងធនធានធម្មជាតិ កសិកម្ម ការបង្កើតចំណូល និងការសន្សំប្រាក់ និងការថែទាំអ្នកជម្ងឺអេដស៍ ឬមានផ្ទុកមេរោគហ៊ីវនៅតាមផ្ទះ។ បច្ចុប្បន្នអង្គការនេះមានបុគ្គលិក ១៥នាក់ និងអ្នកស្ម័គ្រចិត្តចំនួន ៥នាក់។

អាស័យដ្ឋានទំនាក់ទំនង :
ផ្ទះលេខ ២៥៨ ផ្លូវលេខ ៣ សង្កាត់ស្វាយប៉ោ
ខេត្តបាត់ដំបង
ទូរស័ព្ទ : ០៥៣ ៩៥២៤៣៣
អ៊ីម៉េល : asbtb@camintel.com

# ព័ត៌មានពីអង្គការក្រៅរដ្ឋាភិបាល

## » OSMOSE

### ការភ្ជាប់ទំនាក់ទំនងជាមួយការអភិរក្ស ដោយផ្អែកលើសហគមន៍ ទេសចរណ៍ធម្មជាតិ និងការអប់រំបរិស្ថាននៅព្រែកទាល់ បឹងទន្លេសាប



Osmose ជាសមាគមមិនស្វែងរកកំរៃមួយដែលបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៩ បានដំណើរការអនុវត្តគំរោងអភិវឌ្ឍន៍ និងអភិរក្សសាកល្បងនៅក្នុងតំបន់ព្រែកទាល់។ កន្លែងនេះគឺសំរាប់ត្រួតពិនិត្យការជួយសង្គ្រោះពូជបក្សីទឹកមួយចំនួនដែលកំពុងរងការគំរាមកំហែង។ បញ្ហាសំខាន់ដើម្បីបង្ហាញនោះគឺការប្រមូលពងសត្វ និងកូនបក្សីដ៏ច្រើនលើសលប់ដោយអ្នកស្រុក។ គំរោងនេះមានគោលបំណងភ្ជាប់ការអភិរក្សពពួកសត្វបក្សីទឹកដោយបង្កើនការអភិវឌ្ឍន៍សហគមន៍មូលដ្ឋានដោយចីរភាព។ វិធីសាស្ត្រនៅតាមសហគមន៍របស់ OSMOSE ដើម្បីអភិរក្សជាការបំពេញបន្ថែមលើកម្មវិធីអភិរក្សរបស់អង្គការអភិរក្សសត្វព្រៃ (wcs)។

### វិធីសាស្ត្រតែមួយ...

កម្មវិធីរួមរបស់ Osmose និងសហគមន៍អភិរក្សសត្វព្រៃ (wcs) បានបង្កើតយុទ្ធសាស្ត្ររួមគ្នាតាមរយៈសកម្មភាព ៣ប្រភេទ:

- ការអភិរក្ស : ការការពារដោយម៉ត់ចត់នៃហ្វូងបក្សីទឹក តាមរយៈការជួលអ្នកស្រុក ២៥នាក់ធ្វើជាក្រុមអភិរក្សតាមតំបន់ ដោយពាក់កណ្តាលនៃក្រុមនេះ គឺជាអតីតអ្នកចាប់សត្វស្លាប។
- ការអប់រំ : ការសិក្សាអំពីបរិស្ថានក្នុង និងក្រៅថ្នាក់សំរាប់សាលាជាង១២០០ និងក្មេងក្រៅសាលា និងការបំពាក់បំប៉នការយកចិត្តទុកដាក់ និងការបណ្តុះគំនិតឱ្យចេះស្រលាញ់បរិស្ថានធម្មជាតិ។

### ...ឆ្ពោះទៅការអភិវឌ្ឍដោយចីរភាព

- ទេសចរណ៍ធម្មជាតិ : ការរៀបចំដំណើរកំសាន្តទៅកាន់ដែនជំរកសត្វស្លាប និងតាមភូមិជាក្រុមតូចៗក្នុងគោលបំណងដើម្បីផ្តល់លទ្ធភាពដល់អ្នកភូមិទាំងនោះឱ្យមានប្រាក់ចំណូល។

លើសពីនេះ ប្រាក់ចំណូលដែលបានពីទេសចរណ៍ធម្មជាតិត្រូវលៃទុកសំរាប់កម្មវិធីអភិវឌ្ឍន៍នៅមូលដ្ឋានផ្ទាល់។ គោលបំណងនេះដើម្បីផ្គត់ផ្គង់ដល់គ្រួសារដែលមិនអាចទទួលផលប្រយោជន៍ផ្ទាល់ពីសកម្មភាពទេសចរណ៍។ ការផ្តល់ការងារដល់គ្រួសារគោលដៅដែលជាអ្នកក្រីក្រ គឺពិតជាត្រឹមត្រូវ និងជាគោលការណ៍សំដៅដល់ការអភិវឌ្ឍដោយចីរភាព។

### លទ្ធផល

បច្ចុប្បន្នក្រៅពីបក្សីចំនួន៧ប្រភេទត្រូវបានជួយសង្គ្រោះពីការផុតពូជ មានគ្រួសារជាង១០០ គឺស្មើនឹង ១៣%នៃសហគមន៍បានទទួលផលប្រយោជន៍ពីគំរោង ក្នុងនោះមានអតីតអ្នកចាប់សត្វស្លាបចំនួន៣១នាក់ និងស្ត្រី២២នាក់ជាមេផ្ទះ។

### អ្នកដែលទទួលបានផលប្រយោជន៍

ប្រភេទនៃផលប្រយោជន៍ទាំងនោះរួមមាន :

- ការងារ: ឧទ្យានុរក្ស ២៥នាក់ (wcs) បុគ្គលិកគំរោង១២នាក់
- អាហារូបត្ថម្ភ និងប្រាក់ចំណូលបន្ថែម : សួនបណ្តែតទឹក (៥៤)
- ប្រាក់ចំណូលផ្សេងទៀតដែលបានមកផ្អែកទេសចរណ៍ : សេវាកម្មចែវទូក (២០) សិប្បកម្មធ្វើកំប្លោក (១៥) ទស្សនាចរណ៍ភូមិតាមសហគមន៍ (១០គ្រួសារ)



- ជំនួយជាសំភារៈ និងការអប់រំ : ទូកចែវ (២០) ផ្ទះ(៥) សាលារៀន(១០)
- សុខភាព និងអនាម័យៈ កន្លែងពិគ្រោះជំងឺកុមារ ផ្តល់គ្រូពេទ្យព្យាបាល ការដឹកជញ្ជូនអ្នកជំងឺធ្ងន់ដែលត្រូវសង្គ្រោះបន្ទាន់ ប្រដាប់ច្រោះទឹកស្អាត(៤០)

## ស្នារតីរបស់Osmose

ក្នុងខ្លឹមសារនៃកម្មវិធីនេះគឺឱ្យមានការភ្ជាក់រលឹករូបរួមគ្នាស្រលាញ់បរិស្ថាន ដោយផ្តល់អាទិភាពរយៈពេលខ្លី (សង្គ្រោះពពួកសត្វទាំងនោះឱ្យរួចផុតពីការផុតពូជ) កសាងភាពជាម្ចាស់កម្មសិទ្ធិរយៈពេលយូរ (អប់រំឱ្យមានការយល់ដឹងអំពីបរិស្ថាន) និងជំរុញលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច (ក្រុមគោលដៅអាចទទួលបានផលចំណេញដោយផ្ទាល់ និងដោយប្រយោល)។

គំនិតជាគោលសំខាន់របស់ Osmose គឺធ្វើឱ្យបរិស្ថានធម្មជាតិព្រែកទាល់មានលក្ខណៈល្អពិសេស និងមានប្រយោជន៍បំផុតសំរាប់អ្នកភូមិទាំងអស់ធ្វើការអភិវឌ្ឍន៍។ ដើម្បីរំលឹកដល់កម្មវិធីនេះ បក្សីឈើដែលព្យួរនៅតាមផ្ទះរបស់គ្រួសារ Osmose គឺជាការបញ្ជូនសារដ៏ល្អមួយដែលទាក់ទងទៅនឹងការបង្កើនមុខរបរចិញ្ចឹមជីវិតគ្រួសារ និងការអភិរក្សធនធានធម្មជាតិដ៏សំបូរបែបរបស់ពួកគេ។

សកម្មភាពរបស់ Osmose ជាច្រើនបានគ្រោងទុកសំរាប់ឆ្នាំក្រោយៗបន្តទៀតដូចជា :

- បង្កើតយុទ្ធសាស្ត្រសំរាប់ជំរើសមុខរបរចិញ្ចឹមជីវិតសំរាប់គ្រួសារ
- បង្កើនជីវភាពរស់នៅដោយផ្អែកទៅលើសុខភាព
- ការអប់រំ
- កែលំអប្រព័ន្ធអនាម័យ

ការអប់រំ អភិរក្ស និងទេសចរណ៍ធម្មជាតិ

មជ្ឈមណ្ឌលសម វាសនសំរាប់អភិរក្សសត្វព្រៃ

ប្រអប់សំបុត្រ 93045 ខេត្តសៀមរាប កម្ពុជា

ទូរសព្ទ័ : 855 (0)12 832 812 /
855 (0)63 963 710
អ៊ីម៉ែល osmose@online.com.kh



## » អង្គការការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន - L&L

អង្គការការអប់រំស្តីពីការរស់នៅជាមួយបរិស្ថានគឺជាអង្គការដែលស្វែងរកកំរៃ និងជាអង្គការក្រៅរដ្ឋាភិបាលមួយដែលជំរុញលើការយល់ដឹងឱ្យកាន់តែទូលាយ និងធ្វើសកម្មភាពឆ្ពោះទៅកាន់ចីរភាពមនុស្សជាតិ និងបរិស្ថានតាមរយៈការពង្រឹងការអប់រំ និងការពិភាក្សា។ អង្គការនេះទើបតែក្លាយជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយនៅឆ្នាំ ២០០៥នេះ។ គោលបំណងរបស់គេគឺ "ដើម្បីបង្កើនការអភិរក្ស និងការយល់ដឹងពីបរិស្ថានតាមរយៈការអប់រំ ការបណ្តុះបណ្តាល ការតស៊ូមតិ និងសេវាកម្មបរិស្ថានផ្សេងទៀត ដើម្បីគាំទ្រលើការប្រើប្រាស់ដោយសមភាព និងចីរភាពលើធនធានធម្មជាតិ សំរាប់ផលប្រយោជន៍កម្ពុជា"។

អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថានបច្ចុប្បន្នផ្តោតការងាររបស់គេទៅលើយុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិ។ យុទ្ធនាការនេះត្រូវបានបង្កើតឡើងដោយក្រសួងបរិស្ថានដោយទុកជាផ្នែកមួយរបស់គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប។ នៅក្នុងយុទ្ធនាការនេះមានកម្មវិធីចំនួន៧ គឺ:

១, ធ្វើការពិនិត្យលើស្ថានភាពនៃការអប់រំបរិស្ថាន និងព័ត៌មានដែលមាន
២, ការកំនត់ក្រុមគោលដៅ
៣, ការអប់រំ និងផ្តល់ការយល់ដឹងដល់សហគមន៍
៤, ការអប់រំក្នុងប្រព័ន្ធ
៥, ការបោះពុម្ពផ្សាយពីសារៈសំខាន់បរិស្ថានបឹងទន្លេសាប
៦, ការត្រួតពិនិត្យ និងការវាយតំលៃ
៧, វេទិកាពិភាក្សាថ្នាក់ជាតិ។

ការិយាល័យអង្គការនេះឋិតនៅទីក្រុងភ្នំពេញ ពួកគេបានប្រមូលឯកសារបរិស្ថាន និងសំភារៈអប់រំបរិស្ថានអន្តរជាតិ ជាពិសេសទាក់ទងនឹងសកម្មភាពរបស់អង្គការនេះនៅក្នុងប្រទេសផ្សេងទៀត។ បច្ចុប្បន្នពួកគេធ្វើការងារនៅក្នុងខេត្ត៥ នៅជុំវិញបឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង កំពង់ធំ ពោធិ៍សាត់ បាត់ដំបង និងខេត្តសៀមរាប) ហើយអង្គការនេះក៏មានសកម្មភាពជាថ្នាក់ជាតិផងដែរ។

លោក គាត ប៊ុនថាន : មន្ត្រីអប់រំបរិស្ថាន
លោក ជុំ សំអូន : មន្ត្រីផ្នែកសារព័ត៌មាន
ទូរស័ព្ទ: ០២៣ ២២៤ ០៥៣
អ៊ីម៉ែល: livelearn@online.com.kh
គេហទំព័រ http://www.idea.org.au/liveandlearn/
ផ្ទះលេខ៣៦៤ ផ្លូវមុន្នីវង្ស ខណ្ឌចំការមន ក្រុងភ្នំពេញ

# ឋបនីយជីវមណ្ឌល នៅប្រទេសវៀតណាម

ដោយ សូញ៉ា អិនឌុលវីបឺ

កម្មវិធីមនុស្សជាតិ និងជីវមណ្ឌល (MAB) របស់អង្គការ យូណេស្កូ ត្រូវបានបង្កើតឡើងនៅដើមទសវត្សរ៍ទី៧០ ដើម្បីផ្តោតលើទំហំអេកូឡូស៊ី សង្គម និងទំហំសេដ្ឋកិច្ចនៃការបាត់បង់ជីវចម្រុះ និងការថយចុះនូវការបាត់បង់នេះ ។ សព្វថ្ងៃបណ្តាញការងារឋបនីយជីវមណ្ឌលលើពិភពលោកមានជាង ៤៨០កន្លែងនៅក្នុងប្រទេសជាង១០០ ។ មានឋបនីយជីវមណ្ឌលចំនួន១៧ ឋិតនៅអាស៊ីអាគ្នេយ៍ ។ ឥឡូវយើងនឹងមើលទៅប្រទេសវៀតណាមដែលមានឋបនីយជីវមណ្ឌលចំនួន៤ ។




## ឋបនីយជីវមណ្ឌលព្រៃកោងកាងខេនចូ (Can Gio)

ជាឋបនីយជីវមណ្ឌលដំបូងបង្អស់របស់វៀតណាម ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០០។ វាឋិតនៅតំបន់ឆ្នេរភាគអាគ្នេយ៍នៃទីក្រុង ហូជីមិញ ដែលតំបន់នេះមានទំហំ ៧៥.៧៤០ហិកតា។

ខេនចូ គ្របដណ្តប់ដោយប្រភេទព្រៃកោងកាង រួមមានទាំងប្រភេទទឹកប្រៃ និងទឹកភ្លៀវ។ ព្រៃកោងកាងនៅ ខេនចូ មានជីវចម្រុះច្រើនជាមួយនឹងប្រភេទសត្វជាង ២០០ប្រភេទ និងរុក្ខជាតិ ៥២ប្រភេទ។ ការប៉ះពាល់នៃសង្គ្រាមនាពេលថ្មីៗកន្លងទៅនេះលើប្រព័ន្ធអេកូឡូស៊ីបានកំពុងបំផ្លាញ និងកិច្ចប្រឹងប្រែងជាច្រើនត្រូវបានកំពុង អនុវត្តដោយប្រជាជនមូលដ្ឋានដើម្បីកសាងឡើងវិញនូវប្រភេទកោងកាងនៅទីនោះ។ សព្វថ្ងៃវាបានក្លាយជាតំបន់ព្រៃកោងកាងដែលត្រូវបានស្តារឡើងវិញធំជាងគេមួយលើពិភពលោក។

ព្រៃកោងកាងស្តែងចេញនូវមុខងារផ្នែកអេកូឡូស៊ីដ៏មានតំលៃជាច្រើន ដែលក្នុងនោះមានស្ថេរភាពតំបន់ឆ្នេរ និងការការពារប្រឆាំងនឹងការហូរច្រោះដីនៅតាមតំបន់ឆ្នេរ ការកំពប់ប្រេង និងខ្យល់ព្យុះ។ វាជាប្រភពអុស និងសំភារៈសំណង់។ វាលភក់ និងវាលខ្សាច់ជាជំរកដ៏សំខាន់សំរាប់ការបម្លាស់ទីរបស់បក្សីឆ្នេរ។ ព្រៃកោងកាងជា "សួតបៃតង" សំរាប់ទីក្រុងហូជីមិញ។

មានកត្តាគំរាមកំហែងមួយចំនួនលើជីវចម្រុះនៅខេនចូ ដែលបញ្ហាសំខាន់ជាងគេគឺការកាប់ឈើកោងកាងធ្វើជាឈើសំណង់ អុស និងការបម្លែងតំបន់ព្រៃកោងកាងទៅជាស្រះវារីវប្បកម្ម។ បញ្ហាសំខាន់ផ្សេងទៀតគឺ ឥទ្ធិពលរបស់មនុស្ស រួមមាន បច្ចេកទេសនេសាទខុសច្បាប់ ការកំពប់ប្រេង ការបង្ហូរទឹកល្អពីតំបន់ទីប្រជុំជនដែលនៅជិតនោះ។

## ឋបនីយជីវមណ្ឌលខាតទាន (Cat Tien)

ឋបនីយជីវមណ្ឌល ខាតទាន ឋិតនៅភាគខាងត្បូងនៃប្រទេសវៀតណាម។ ឋបនីយជីវមណ្ឌលនេះមានទំហំសរុប ២៥៧.៣៥៧ហិកតា រួមបញ្ចូលទាំងឧទ្យានជាតិ ខាតទាន ដែលឋិតនៅក្នុងតំបន់ស្នូល។

ឧទ្យានជាតិ ខាតទាន ផ្តល់ជាប្រភេទជំរកផ្សេងៗ ដែលក្នុងនោះមានវាលទំនាបព្រៃបៃតងអចិន្ត្រៃយ៍ដំបូង និងព្រៃដាំឡើងវិញ ព្រៃជ្រុះស្លឹកដែលដាំឡើងវិញ តំបន់ដីសើមជាមួយនឹងផ្ទៃបឹង និងវាលស្មៅលិចទឹកតាមរដូវព្រៃលិចទឹក និងពពួកប្រភេទជំរកដែលដុះឡើងវិញ រួមមានវាលស្មៅ និងតំបន់ដែលសំបូរ



▲ រមាសកុយ១ នៅក្នុងឋបនីយជីវមណ្ឌលខាតទាន



▲ ឋបនីយជីវមណ្ឌលដាវខាតបាត្រូវបានស្គាល់ដោយសារភូមិសណ្ឋានកាសថ៌កំបោររបស់វា

ដោយព្រៃឫស្សី។ ខាតទាន ជាតំបន់ដែលសំខាន់ មួយសំរាប់ការអភិរក្សប្រភេទបក្សីសត្វធំៗនៅវៀតណាម ដែលក្នុងនោះប្រភេទដែលសំខាន់ជាងគេគឺ រមាសកុយមួយ។

ជីវចម្រុះនៅបរិមណ្ឌលជីវមណ្ឌលត្រូវបានគំរាមកំហែងដោយ ១) ការប្រែក្លាយដីព្រៃទៅជាដីកសិកម្ម ការថយចុះទីជំរកប្រភេទសត្វដែលកំពុងរងការគំរាមកំហែងជាសាកល ២) ការធ្វើអាជីវកម្មខុសច្បាប់លើឈើមូលផ្តៅបក្សីសត្វ សត្វស្លាប និងមច្ឆា ៣) ខ្វះខាតការសំរបសំរួលក្នុងចំណោមភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋានផ្សេងៗ លទ្ធផលពីការបង្កើតការអភិវឌ្ឍន៍កសិកម្មជំនួសឱ្យការអភិរក្សជីវចម្រុះ និង ៤) ផែនការសង់ទំនប់វារីអគ្គិសនីនៅ ភាគខាងលើឧទ្យានជាតិ ខាតទាន។

គំរោងអភិរក្សកំពុងឋិតនៅជាមួយនឹងទិសដៅនៃការអភិរក្សព្រៃតំបន់ត្រូពិចដែលនៅសល់ ការរក្សាចំនួនផ្សេងៗនៃប្រភេទរមាសកុយមួយ ការការពារផ្នែកមិនស្អាតនៃផ្លូវទឹកភ្លៀង ទ្រីអាន ការពង្រឹងការយល់ដឹងជាសាធារណៈ និងធ្វើឱ្យប្រសើរឡើងនូវឱកាសរកប្រាក់ចំនូលសំរាប់ប្រជាជនមូលដ្ឋាន។

## បរិមណ្ឌលជីវមណ្ឌលដាវខាតបា

(Dao Cat Ba)

បរិមណ្ឌលជីវមណ្ឌល ដាវខាតបា ជាទីប្រជុំកោះថ្មកំបោរ ចំនួន៣៦៦ នៅភាគខាងជើងនៃប្រទេសវៀតណាម ដែលមាន សារៈសំខាន់ជាអន្តរជាតិទៅលើលក្ខណៈភូ មិសណ្ឋានកាស (តំបន់ថ្មកំបោរ) របស់វា និងជាគំរូដ៏ល្អជាងគេមួយនៅលើ ពិភពលោកទៅលើទេសភាពដែលលាតសន្ធឹងលើផ្ទៃសមុទ្រ។ កោះធំៗភាគច្រើនគ្របដណ្តប់ដោយព្រៃបៃតងជានិច្ចតំបន់ត្រូពិច។ កោះថ្មកំបោរដែលធំជាងគេមានទំហំ ២៨៥គីឡូម៉ែត្រក្រឡា និងរួមបញ្ចូលទាំងឧទ្យានជាតិ ខាតបា។

ខាតបា ព័ទ្ធជុំវិញនូវផ្នែកតូចៗនៃប្រភេទគំរបដីដែលជាប្រភេទដីទំនាប និងព្រៃឈើកាសថ្មកំបោរ ព្រៃតំបន់ថ្មកំបោរ តំបន់កសិកម្ម ព្រៃឫស្សី ព្រៃកោងកាង និងស្មៅសមុទ្រ។ តំបន់ប្រជុំកោះនេះមានសារៈសំខាន់ជាសាកលដោយសារតែវាសំបូរប្រភេទសត្វដែលគេកម្រជួបនៅតាមតំបន់ផ្សេងៗទៀត។ ស្វាក្បាលពណ៌មាសជាគំរូមួយនៃប្រភេទដែលមានប្រចាំតំបន់កោះ ខាតបា ដែលត្រូវបានចុះបញ្ជីថាជាប្រភេទមួយក្នុងចំណោមវានរជាតិទាំងដប់ដែលកម្របំផុតនៅលើពិភពលោក។ មានចំនួនប្រភេទជីវកសំខាន់ៗប្រចាំតំបន់ផងដែរ ដែលរួមមានតំបន់ផ្កាថ្ម ព្រៃកោងកាង ស្មៅសមុទ្រ ព្រៃវាលភក់ និងព្រៃថ្មកំបោរតំបន់ត្រូពិក។

មានកត្តាគំរាមកំហែងធំៗមួយចំនួនទៅលើជីវចម្រុះនៅបរិមណ្ឌលជីវមណ្ឌល ដាវខាតបា។ ផ្កាថ្មនៅតំបន់ដែលកំពុងរងការគំរាមកំហែងដោយទឹកប្រៃ ការនេសាទដោយគ្រឿងផ្ទុះ និង

## ខេនចូមានតំបន់ព្រៃកោងកាងដែលស្តារឡើងវិញធំជាងគេបង្អស់លើពិភពលោក

ការជីកដី។ ផលស្តុកត្រីកំពុងត្រូវបានបំផ្លាញដោយការនេសាទដែលមិនធានានូវចីរភាព រួមមានការប្រើប្រាស់ប្រភេទសៃ្បមុង ការបំពុល និងការនេសាទដោយឆក់។ បរិស្ថានតំបន់ទឹកប្រៃកំពុងរងការបំពុលដោយការធ្វើចរាចរតាមសមុទ្រ និងទទួលឥទ្ធិពលពីវារីវប្បកម្ម និងដីកសិកម្ម។

## បរិមណ្ឌលជីវមណ្ឌលដីសណ្តទន្លេក្រហម

ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៤ និងតាំងនៅភាគខាងជើងប្រទេសវៀតណាម ដែលបរិមណ្ឌលជីវមណ្ឌលដីសណ្តទន្លេក្រហមនេះមានតំបន់ដីសើមដែលមានសារៈសំខាន់ជាសាកល រួមមាន តំបន់ដីសើម សួយ ធុយ ដែលជាតំបន់រាមសារដំបូងបំផុតរបស់ប្រទេសវៀតណាម។

ប្រភេទទីជំរកនៅក្នុងបរិមណ្ឌលជីវមណ្ឌលដែលមានជីវចម្រុះមានតំលៃធំធេង គឺជាប្រភេទព្រៃកោងកាងធម្មជាតិ និងវាលភក់ដែលមិនត្រូវបានរំខាន។ ជាលទ្ធផលនានាភាពនៃជំរក និងទំនាក់ទំនងធម្មជាតិបរិសុទ្ធនៃដីសណ្តទន្លេក្រហមជាតំបន់សំរាប់បង្កើត និងការតាំងនៅនៃពពួកបក្សីដែលធ្វើការបម្លាស់ទីតាមរដូវ។ ក្នុងកំឡុងពេលនៃការផ្លាស់ទីនៅរដូវផ្ការីក និងរដូវស្លឹកឈើលាស់ ចំនួនដ៏ច្រើននៃពពួកសត្វស្លាបបានធ្វើដំណើរមកឈប់តាំងទីនៅចន្លោះតំបន់ដែលជាជំរកពងកូនរបស់វានៅតំបន់អាស៊ីខាងជើង និងតំបន់ដែលវារស់នៅឥណ្ឌូម៉ាឡេស៊ី និងតំបន់អូស្ត្រាលី។ បរិមណ្ឌលជីវមណ្ឌលជាតំបន់សំរាប់រស់នៅសំខាន់ជាងគេមួយសំរាប់សត្វ ត្រនាលជិតុះស្លាបព្រា (Black-face Spoonbill) ប្រភេទសត្វនេះត្រូវបានប៉ាន់ប្រមាណថាមានចំនួនត្រឹមតែ ៣២៣ប៉ុណ្ណោះលើពិភពលោក។ មានការគំរាមកំហែងមួយចំនួនលើការអភិរក្សនៅតំបន់ដីសណ្តទន្លេក្រហម។ បញ្ហាធ្ងន់ធ្ងរជាងគេគឺតំបន់វាលភក់ដែលត្រូវបានចាត់ទុកជាកន្លែងរកចំណីរបស់ពពួកសត្វ ត្រនាលជិតុះស្លាបព្រា និងប្រភេទសត្វស្លាបដែលកំពុងរងការគំរាមកំហែងជាសាកលមួយចំនួន ម្យ៉ាងទៀតតំបន់វាលភក់នេះកំពុងត្រូវបានគេដាំព្រៃកោងកាងក្នុងគោលបំណងថែរក្សាដី និងការពារ-ច្រាំង។ បញ្ហាទាំងនេះធ្វើអោយប្រែប្រួលលក្ខណៈដើមរបស់ស្រទាប់ដី និងគំរាមកំហែងដល់ការធ្វើឱ្យតំបន់នេះគ្មានចីរភាពសំរាប់ប្រភេទសត្វស្លាបដែលរងការគំរាមកំហែង-ជាសាកល។ បន្ថែមលើនេះទៀត កោះខ្សាច់ដែលឋិតនៅជាធម្មជាតិត្រូវបានកំពុងបណ្តុះប្រភេទព្រៃឈើថ្មីៗ ដែលនាំឱ្យមានការកាត់បន្ថយលើប្រភេទជំរកធម្មជាតិ។ ការគំរាមកំហែងដែលបន្ថែមលើនេះទៅលើ ការអភិរក្សជាការធ្វើវារីវប្បកម្ម និងកំរិតនៃការនេសាទ និងការប្រមូលពពួកបណ្តុំសត្វនៅតាមមាត់ច្រាំង។ ផ្នែកអេកូឡូស៊ីព្រៃកោងកាង និងការស្រាវជ្រាវ (MERD) នៃមជ្ឈមណ្ឌលសំរាប់ការសិក្សាពីបរិស្ថាន និងធនធានធម្មជាតិ (CRES) សព្វថ្ងៃកំពុងអភិវឌ្ឍន៍លើគំរោងខ្នាតតូចរបស់ មូលនិធិបរិស្ថានពិភពលោក (GEF) តាមរយៈគំរោងអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP)។ គោលបំណងគំរោងនេះនឹងធ្វើការអភិរក្សក្នុងរយៈពេលយូរ និងការប្រើប្រាស់ប្រកបដោយចីរភាពលើជីវចម្រុះនៅក្នុងតំបន់ឆ្នេរនៃតំបន់ដីសណ្តទន្លេក្រហម។

តំបន់បីទៀតគឺ គៀនយ៉ាំង (Kien Giang) ង៉ែអាន (NgheAn) និងថាញ់ហាវ (Thanh Hoa) ត្រូវបានស្នើឡើងសំរាប់បង្កើតជាបរិមណ្ឌលជីវមណ្ឌលនៅប្រទេសវៀតណាម។

អំណានបន្ថែម : បណ្តាញការងារបរិមណ្ឌលជីវមណ្ឌលវៀតណាម : http://mabvn.net/Biosphere.htm UNESCO Man and Biosphere Program: http://www.unesco.org/mab/index.shtml

# ការបោះពុម្ពផ្សាយ









## របាយការណ៍ស្ថានភាពនៃការអប់រំបរិស្ថានឆ្នាំ ២០០៥

បោះពុម្ពដោយក្រសួងបរិស្ថាន និង អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន

ខែឧសភា ២០០៦

របាយការណ៍ដំបូងស្តីពីស្ថានភាពប្រទេសកម្ពុជាទៅលើការអប់រំបរិស្ថាន ធ្វើការបង្ហាញពីការងារជាអាទិភាព សំរាប់វិធីសាស្ត្រជាយុទ្ធសាស្ត្រដើម្បីអប់រំ។ ក្នុងរបាយការណ៍នេះមានយុទ្ធសាស្ត្រចំនួនប្រាំបីសំរាប់វិធីសាស្ត្រជាយុទ្ធសាស្ត្រក្នុងការអប់រំបរិស្ថាន។ វិធីសាស្ត្រនេះទាមទារនូវការ ធ្វើការងារជាមួយជនគោលដៅ ការប្រើប្រាស់ ភាសាដោយប្រុងប្រយត្ន័និងការផ្លាស់ប្តូរអាកប្បកិរិយាប្រជាជន។ របាយការណ៍នេះក៏បានផ្តល់អនុសាសន៍លើការពង្រីកការអប់រំ និងផ្តោតធ្ងន់លើលទ្ធផលក្នុងរយៈពេលវែង ជាជាងលទ្ធផលជាក់លាក់ក្នុងរយៈពេលខ្លី ពីគំរោង។ អនុសាសន៍ផ្សេងទៀតរួមមានការធ្វើឱ្យប្រសើរឡើងលើកិច្ចសហការរវាងដៃគូអភិវឌ្ឍន៍ បង្កើតការវាយតំលៃលើសកម្មភាព និងសំភារៈអប់រំបរិស្ថាននិងធ្វើការនាំមុខដោយធ្វើជាគំរូ។

របាយការណ៍នេះត្រូវបានរៀបចំឡើងសំរាប់ក្រសួងបរិស្ថាន ដោយអង្គការការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន (Live&Learn) ដែលជាផ្នែកមួយនៃយុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិដែលមានរយៈពេល ១៨ខែ នៅក្រោមគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប។

មានជាភាសាខ្មែរ និងអង់គ្លេសនៅ Live & Learn

ទូរសព្ទ័ ៨៥៥ ២៣ ២២៤ ០៥៣

អ៊ីម៉ែល : livelearn@online.kh

## បឹងទន្លេសាប

បោះពុម្ពផ្សាយដោយ WCS

២០០៦

សៀវភៅថ្មីអំពីបឹងទន្លេសាបទើបតែបានបោះពុម្ព។ "ទន្លេសាប : កេរដំណែលធម្មជាតិនៃបេះដូងកម្ពុជា" ត្រូវបាននិពន្ធដោយកូលីនភូល ប្រធានកម្មវិធីអាស៊ីសំរាប់អង្គការអភិរក្សសត្វព្រៃ (WCS)។ ដែលរស់នៅកម្ពុជាអស់ប្រាំបីឆ្នាំ និង អេលីន័រ ប្រ៊ីក ដែលធ្វើការងារថតរូបពីបឹងទន្លេសាបអស់រយៈពេលជាង១០ឆ្នាំមកហើយ។ តាមរយៈអត្ថបទ និងការអះអាងដែលបានចេញផ្សាយ និងរូបភាពដែលគួរអោយចងចាំទាំងនេះបញ្ចូលគ្នា ពួកគេបានធ្វើការលើកជាឧទាហរណ៍ពីគ្រប់ចំនុចទាំងអស់នៃទន្លេសាប និងភាពគួរអោយចាប់អារម្មណ៍នៃប្រទេសកម្ពុជា និងបរិស្ថានស្រស់ស្អាតអំពីពពួលសត្វ ប្រវត្តិសាស្ត្រ វប្បធម៌ និងអនាគតរបស់ប្រទេសនេះ។

មាននៅ Monument Books

## សៀវភៅស្តើងៗស្តីពីជំបនីយជីវមណ្ឌលបឹងទន្លេសាប

បោះពុម្ពដោយលេខាធិការដ្ឋានជំបនីយជីវមណ្ឌលបឹងទន្លេសាប ២០០៦

បឹងទន្លេសាបត្រូវបានកំណត់ជាជំបនីយជីវមណ្ឌលរបស់អង្គការសហប្រជាជាតិសំរាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (UNESCO) នៅឆ្នាំ១៩៩៧។ បឹងទន្លេសាបជាបឹងទឹកសាបដែលធំជាងគេនៅអាស៊ី–អាគ្នេយ៍ដែលមាន វាលព្រៃលិចទឹកតាមរដូវធំជាងគេ និងបន្ទាយសត្វស្លាបទឹកកម្រធំជាងគេ។ បឹងនេះជាបឹងដែលផ្តល់ទិន្នផលទឹកសាបច្រើនជាងគេលើពិភពលោក។ សៀវភៅស្តើងនេះបានបោះពុម្ពដោយលេខាធិការដ្ឋានជំបនីយជីវមណ្ឌលបឹងទន្លេសាប បង្ហាញពីតម្លៃធម្មជាតិ សេដ្ឋកិច្ច និងតំលៃវប្បធម៌នៃបឹងទន្លេសាបដែលមានសារៈសំខាន់ជាសាកល។

គោលបំណងនៃការបោះពុម្ពផ្សាយនេះគឺដើម្បីធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងក្នុងចំណោមប្រជាជនកម្ពុជា និងអ្នកដែលចាប់អារម្មណ៍ពីជំបនីយជីវមណ្ឌល។ វាក៏មានគោលបំណងដើម្បីលើកកំពស់ការយល់ដឹង និងបង្កើនការធ្វើសេចក្តីសំរេចចិត្តដល់អ្នកបង្កើតគោលនយោបាយ ដោយផ្តល់ឱ្យពួកគាត់នូវព័ត៌មានទូលំទូលាយស្តីពីតួនាទីវប្បធម៌ និងប្រព័ន្ធអេកូឡូស៊ីតែមួយនៃបឹងទន្លេសាប។

មាននៅលេខាធិការដ្ឋានជំបនីយជីវមណ្ឌល–បឹងទន្លេសាប

ទូរស័ព្ទ : (៨៥៥–០២៣) ២២១ ០៧៩

អ៊ីម៉ែល : secretariat@tsbr-ed.org

## ដើម្បីផ្សាយពីការបោះពុម្ពរបស់អ្នក

សូមទំនាក់ទំនងមក លេខាធិការដ្ឋានជំបនីយជីវមណ្ឌលបឹងទន្លេសាប

ទូរស័ព្ទ : (៨៥៥–០២៣) ២២១ ០៧៩ អ៊ីម៉ែល : secretariat@tsbr-ed.org

# ប្រតិទិន

## ទិវាមច្ឆាជាតិ

ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០០៦
ទីកន្លែង : ក្រុងព្រះសីហនុ
អាស័យដ្ឋានទំនាក់ទំនង : ការិយាល័យរដ្ឋបាលនៃនាយកដ្ឋានជលផល
ទូរស័ព្ទ : ០១២ ៥៦៣៥៥៩

ទិវាមច្ឆាជាតិគ្រោងនឹងប្រារព្ធធ្វើនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៦ ក្រោមអធិបតីភាពសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។
ពិធីនេះនឹងប្រារព្ធធ្វើនៅក្នុងឧទ្យានព្រៃឈើក្រុងព្រះសីហនុ ដោយមានការចូលរួមពីសំណាក់មន្ត្រីរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន តំណាងទូត និងអង្គការក្រៅរដ្ឋាភិបាល។

## ពិធីបុណ្យអុំទូក

ថ្ងៃទី ០៤-០៦ ខែវិច្ឆិកា ឆ្នាំ២០០៦
ទីកន្លែង : រាជធានីភ្នំពេញ
អាស័យដ្ឋានទំនាក់ទំនង : ក្រសួងធម្មការ និងសាសនា
ទូរស័ព្ទ : ០២៣ ៧២៥០៩៩

ពិធីបុណ្យអុំទូករយៈពេល៣ថ្ងៃ ដែលនឹងចាប់ផ្តើមនៅថ្ងៃទី០៤ គឺជាពិធីធំជាងគេក្នុងព្រះរាជាណាចក្រកម្ពុជា ជាពេលដែលចរន្តទឹកទន្លេមេគង្គហូរចូលទៅក្នុងបឹងទន្លេសាបវិញ។ ពិធីនេះប្រារព្ធធ្វើឡើងក្នុងពេលខែពេញបវរណ៍មី ដោយមានរៀបចំការប្រណាំងទូកងក្រោមព្រះរាជឧបត្ថម្ភនៃព្រះមហាក្សត្ររួមទាំងការលយប្រទីប សំពះព្រះខែ និងអុជកាំជ្រួចផងដែរ។ ពិធីបុណ្យនេះក៏ជាសញ្ញាបង្ហាញពីការចាប់ផ្តើមនៃរដូវនេសាទ ទន្ទឹមនឹងការប្រមូលផលស្រូវដំណើប និងការដាល់អំបុកឈានចូលមកដល់ (អកអំបុក សំពះព្រះខែ) ។



## ពិព័រណ៍វប្បធម៌ពិភពលោក អង្គរ-យ៉ុងយូ

ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៦ ដល់ថ្ងៃទី៩ ខែមករា ឆ្នាំ២០០៧
ទីកន្លែង : ទីក្រុងសៀមរាប
អាស័យដ្ឋានទំនាក់ទំនង : ក្រសួងទេសចរណ៍
ទូរស័ព្ទ : ០២៣ ៤២៦១០៧

ក្រសួងទេសចរណ៍មានគំរោងនឹងរៀបចំពិធីតាំងពិព័រណ៍វប្បធម៌ពិភពលោក អង្គរ - យ៉ុងយូ ២០០៦ ចំនួន៥០ថ្ងៃ នៅខេត្តសៀមរាប លើផ្ទៃដីទំហំ ១៥ហ.ត។ គេរំពឹងថានឹងមានប្រទេសជាងម្ភៃនឹងមកចូលរួម ហើយក្នុងនោះនឹងមានការរៀបចំឱ្យមានការសម្តែងសិល្បៈ។ ទាំងខាងកម្ពុជា និងកូរ៉េ គឺសម្តែងពិសេសរាល់ថ្ងៃ។ ហើយក៏មានកន្លែងសម្តែងសិល្បៈរបស់ពិភពលោក មានការបង្ហោះខ្លែងអន្តរជាតិដែលមាន ១៧ ប្រទេសចូលរួម។ ជាងនេះទៀតនឹងមានរៀបចំបញ្ចាំងខ្សែភាពយន្តជាលក្ខណៈពិភពលោក ព្រមទាំងមានការបង្ហាញ ម៉ូតសម្លៀកបំពាក់ក្នុងពេលនោះផងដែរ។ ស្តង់ចំនួន ៤០០ ដើម្បីធ្វើការឃោសនាពិព័រណ៍នេះក៏គ្រោងនឹងសាងសង់ឡើងដែរ។



ក្នុងករណីដែលឯកឧត្តម លោកជំទាវ លោក-លោកស្រី មានបំណងចង់ផ្សព្វផ្សាយព្រឹត្តិការណ៍ទាក់ទងនឹងតំបន់ទន្លេសាប
សូមទំនាក់ទំនងជាមួយ លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប
ទូរស័ព្ទ : (៨៥៥-០២៣) ២២១០៧៩ អ៊ីម៉េល : secretariat@tsbr-ed.org

## ពិធីសម្ពោធមជ្ឈមណ្ឌលគ្រប់គ្រងបណ្តែតទឹក

**ដោយ ប្រាម មីល័រ** (BRAM MILLER)

មជ្ឈមណ្ឌលគ្រប់គ្រងបណ្តែតទឹកនៅកំពង់ឆ្នាំង និងតំបន់ស្នូលស្ទឹងសែនត្រូវបានបើកជាផ្លូវការកាលពីថ្ងៃទី១៧ ខែមិនាកន្លងទៅ។ ថវិកាសាងសង់អាគារនេះត្រូវបានផ្តល់ដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អង្គការ UNDP និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទុកផ្នែកមួយនៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (TSEMP) ។

ពិធីសម្ពោធនេះត្រូវបានចូលរួមដោយមនុស្សជាង ៣០០នាក់ រួមមានតំណាងដែលអញ្ជើញមកពីអង្គការ UNDP គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (TSEMP) និងសមាជិកសហគមន៍មូលដ្ឋាន។ បទសន្ទរកថាត្រូវបានធ្វើឡើងដោយអ្នកចូលរួមផ្សេងៗជាច្រើនរូបក្នុងព្រឹត្តិការណ៍ដែលគួរអោយចំណាប់អារម្មណ៍នៅមជ្ឈមណ្ឌលខេត្តកំពង់ឆ្នាំងនេះ។ ពិធីកាត់ខ្សែបូរនេះត្រូវបានប្រព្រឹត្តិទៅនៅក្នុងមជ្ឈមណ្ឌលទាំងពីរ ។

មជ្ឈមណ្ឌលគ្រប់គ្រងស្ទឹងសែននឹងត្រូវបានគេប្រើប្រាស់ជាមូលដ្ឋានសំរាប់អ្នកអនុរក្សដែលគ្រប់គ្រងតំបន់ស្នូល និងជាកន្លែងផ្តោតទៅលើសកម្មភាពអប់រំបរិស្ថានផងដែរ។ តួនាទីសំខាន់សំរាប់មណ្ឌលខេត្តកំពង់ឆ្នាំងគឺសំរាប់អប់រំបរិស្ថាន។ មជ្ឈមណ្ឌលទាំងពីរត្រូវបានបំពាក់គ្រឿងបរិក្ខាយ៉ាងល្អ។ ដែលមានសាលប្រជុំ ការិយាល័យ ឃ្លាំងទុកឥវ៉ាន់ បន្ទប់ទឹក បង្គន់ស្តុកទឹកស្អុយ បន្ទប់ចំអិនអាហារ បន្ទប់ដេកជាច្រើន និងទីលានប្រក់ដំបូល។ គ្រឿងបរិក្ខាទាំងអស់នេះអាចអូសចេញពីកន្លែងមួយទៅកន្លែងមួយទៀតបាន ទោះជាបច្ចុប្បន្នមានទីតាំងនៅកន្លែងនេះក៏ដោយ។

មជ្ឈមណ្ឌលគ្រប់គ្រងថ្មី នៅក្នុងខេត្តពោធិសាត់ (ជាមជ្ឈមណ្ឌលបណ្តែតទឹកដែរ) និងនៅតំបន់ស្នូល ព្រែកទាល់ (ជាផ្ទះមានជើងសរសរ) ក៏មានបំពាក់គ្រឿងបរិក្ខាដូចគ្នា ហើយដែលត្រូវបានកំពុងប្រើប្រាស់។ មជ្ឈមណ្ឌលមួយទៀតដែលមានជើងសសរត្រូវបាន និងកំពុងសាងសង់បន្ថែមផងដែរនៅតំបនស្នូលបឹងទន្លេឆ្មារ ។





VOLUME 1 JULY 2006

## IN THIS EDITION

- Water Snake Trade
- TSBR Common Policy Framework
- NGO update

# TONLE SAP BIOSPHERE RESERVE BULLETIN






VOLUME 1 JULY 2006

Cover Image: Floating village of Prek Toal on the Tonle Sap Lake Photograph by Sonja Endlweber

Published by Tonle Sap Biosphere Reserve Secretariat
# 364, Preah Monivong Boulevard
Phnom Penh, Camodia
Tel: (855-023) 221079
Email: secretariat@tsbr-ed.org
July 2006

This publications forms part of the Tonle Sap Environmental Management Project, provided by an ADB financed loan to the Royal Government of Cambodia.

Edited by Neou Bonheur and Sonja Endlweber
Khmer translations by:
San Phalla and Pich Sokdany
Proofed by Pich Sokdany and Ly Sophorn
Printed by Kim Long Printing House
Design and Layout by Karen Young, Live & Learn Environmental Education

## Letter from the editor



The Tonle Sap Biosphere Reserve is one of Cambodia's most valuable natural assets. It provides fish protein and irrigation water for a majority of the population of Cambodia and boasts unique biodiversity. The TSBR Secretariat was established to foster cooperation, communication and knowledge exchange among all stakeholders.

The Tonle Sap Biosphere Reserve Bulletin, published by the Tonle Sap Biosphere Reserve Secretariat, is part of the overall strategy to improve and increase the knowledge and understanding of decision and policy makers, the technical officers and the public about the unique natural ecosystem and its value by providing them with comprehensive and up-to-date information. This Tonle Sap Bulletin is a sub-output of a Tonle Sap Biosphere Reserve Database funded by the Tonle Sap Environmental Management Project.

From scientific research news, to project updates and information by a wide range of stakeholders working in the Biosphere Reserve, the Bulletin is intented to bring up the most interesting topics, critical issues and problems faced by the Tonle Sap Lake. In addition the Bulletin will provide a space for stories about the life of rural people who make a living from the natural resources of the Lake. It is a platform for interactive discussion and dialogue through sharing the views and concerns from individuals, scientists and social groups. No doubt data and information are the vehicle for progress in all aspects of society. Your contributions in form of articles, reports, livelihood stories and project results are highly welcomed. Your feedback on the current issue is very much appreciated.

This Bulletin is also available for download from our website: www.tsbr-ed.org

Hope you will find the TSBR Bulleting both interesting and informative.

**Neou Bonheur**
Permanent Deputy Director of TSBRS and
National Director of TSEMP

If you would like to submit a story, announce an event or a publication or comment on an article please contact the editor on Tel: (855-023) 221079.
If you would like to be added to the mailing list and receive an electronic copy of the TSBR Bulletin please send an Email to secretariat@tsbr-ed.org.
The Bulletin can be downloaded from the TSBR Web-Page: www.tsbr-ed.org

# ព្រឹត្តិបត្រ

# ថបនីយជីវមណ្ឌលបឹងទន្លេសាប

លេខ ១ ខែកក្កដា ឆ្នាំ ២០០៦



## មាតិកា

ការអភិរក្សសត្វស្លាប ..... ២

ការជួញដូរពស់ទឹក ..... ៤

គំរោងនានា

- ក្របខណ្ឌគោលនយោបាយរួម និងយន្តការសំរបសំរួលរបស់ថបនីយជីវមណ្ឌលបឹងទន្លេសាប ..... ៦
- គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ..... ១០
- ក្រុមអ្នកការពារពិភពលោក ..... ១២
- ប្រព័ន្ធទិន្នន័យ-ព័ត៌មានបរិស្ថាន ..... ១៣
- សហគមន៍នេសាទនៅភូមិស្ពានក្រុង ..... ១៤
- ការបណ្តុះបណ្តាលសំរាប់ការងារគ្រប់គ្រងជីវចំរុះអោយកាន់តែប្រសើរឡើងនៅតំបន់ស្នូល នៃថបនីយជីវមណ្ឌលបឹងទន្លេសាប ..... ១៥
- បច្ចុប្បន្នភាពពីផ្នែកអនុវត្តគំរោងនៅខេត្តកំពង់ឆ្នាំង ..... ១៦
- ការអប់រំបរិស្ថាន ..... ១៧
- ការទ្រទ្រង់ការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយចេរភាពនៅតំបន់ស្នូលថបនីយជីវមណ្ឌល បឹងទន្លេសាប ..... ១៨
- ល្ខោនបរិស្ថានតាមសហគមន៍នៅបេះដូងនៃប្រទេសកម្ពុជា ..... ១៩

ព័ត៌មានពីអង្គការក្រៅរដ្ឋាភិបាល ..... ២០

ថបនីយជីវមណ្ឌលនៅប្រទេសវៀតណាម ..... ២៤

ការបោះពុម្ពផ្សាយ ..... ២៦

ប្រតិទិននៃព្រឹត្តិការណ៍ ..... ២៧

# ការអភិរក្សសត្វស្លាប

## រឿងជោគជ័យនៅតំបន់ស្នូលព្រែកទាល់

មានរឿងជាច្រើនត្រូវបាន និងកំពុង–សរសេរអំពីបឹងទន្លេសាប។ វាចាប់ផ្តើមតាំងពីជាងមួយទស្សវត្សរ៍កន្លងមក ជាមួយអត្ថបទ–មួយ រឺពីរ ដែលលើកឡើងពីចំណាប់អារម្មណ៍របស់ប្រជាជននៃសារៈសំខាន់បឹង។ សព្វថ្ងៃនេះ វាអាចរកឃើញមាននៅក្នុងទស្សនាវដ្តីដំណើរកំសាន្តក្នុងតំបន់ កម្មវិធីវិទ្យុ ទូរទស្សន៍ និងនៅលើកាសែតអន្តរជាតិនានា។

ភាគច្រើននៃរឿងទាំងនេះគឺផ្សព្វផ្សាយពីសារៈសំខាន់ក្នុងពីររបស់បឹងទន្លេសាប រឺបង្ហាញពីផលវិបាកសង្គម និងបរិស្ថាន។ ជាក់ស្តែងនោះគឺជារឿងទាំងឡាយដែលមានទិន្នន័យច្បាស់លាស់ដែលទទួលបាននាពេលកន្លងមកពីបណ្តាគំរោងដែលទាក់ទងនឹងសង្គម ការអភិវឌ្ឍ និងបរិស្ថានរហូតដល់បច្ចុប្បន្ន។

តាមរយៈការប្រើប្រាស់ទិន្នន័យប្រៀបធៀបអស់រយៈពេលជាងបួនឆ្នាំមកនេះ បច្ចុប្បន្ន មានគំរោងមួយមានអត្ថភាព និងទទួលបានលទ្ធផលល្អក្នុងការរៀបចំអត្ថបទនានាដែលទាក់ទងនឹងបឹងទន្លេសាប។ នៅតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទាល់ ដែលជាតំបន់ស្នូលមួយក្នុងចំណោមតំបន់ស្នូលបីនៃ



ឋបនីយជីវមណ្ឌលបឹងទន្លេសាប និងជាឡូតិ៍នេសាទដ៏សំខាន់ដែលកម្ពុជាអាចមានមោទនភាពទៅលើជោគជ័យនៃការស្តារឡើងវិញនូវសោកនាដ្ឋកម្មសត្វព្រៃនៅអាស៊ីអាគ្នេយ៍។

**តារាង១.** ផ្តល់ឧទាហរណ៍មួយនៃហេតុផលដែលព្រែកទាល់មានការលេចធ្លោនៅលើពិភពលោកនៅក្នុងការអភិរក្ស។

ព្រែកទាល់ក៏មានផ្ទុកនូវបន្ទាយសត្វស្លាបទឹកដែលរងការគំរាមកំហែង រឺជិតរងការគំរាមកំហែងដ៏ធំបំផុតមួយនៅអាស៊ីអាគ្នេយ៍។

កម្មវិធីតាមដានត្រួតពិនិត្យលំអិតអាចធ្វើការបង្ហាញយ៉ាងច្បាស់ពីតួលេខកើនឡើងនៃចំនួនប្រជាជន និងតួលេខថយចុះនៃសកម្មភាពបំផ្លាញ ដែលទាំងនេះបានបង្ហាញជាភស្តុតាងច្បាស់លាស់នៃជោគជ័យរបស់គំរោងកន្លងមក។ ការពិនិត្យតាមដាននេះមានសារៈសំខាន់មិនត្រឹមតែអាចនិយាយបានថា "ពួកយើងជោគជ័យ" ប៉ុណ្ណោះទេ ប៉ុន្តែដើម្បីមានលទ្ធភាពក្នុងការគ្រប់គ្រងការផ្លាស់ប្តូរការគំរាមកំហែង និងបន្ទាយសត្វផងដែរ។

គំរោងនេះមានការចាប់ផ្តើមដ៏ល្អជាមួយនឹងរឿងរ៉ាវជោគជ័យនៃការអភិរក្សភាគច្រើន។ ការសិក្សាស្រាវជ្រាវនៅឆ្នាំ ១៩៩៤ ដំបូងឡើងបានសំគាល់ព្រែកទាល់ជាតំបន់ដែលមានសារៈសំខាន់សំរាប់សត្វស្លាបទឹក ប៉ុន្តែក៏ត្រូវបានព្រមានថា ការប្រមូលពងសត្វដោយមិនបានត្រួតពិនិត្យ បានកំពុងគំរាមកំហែង និងបំផ្លិចបំផ្លាញទាំងស្រុងទៅលើប្រភេទសត្វដែលជិតផុតពូជទាំងនេះផងដែរ។ ទស្សនកិច្ចពេលក្រោយទៀតបានកំនត់ថាសកម្មភាពអភិរក្សត្រូវតែបង្កើតជាបន្ទាន់ ដែលកំឡុងពេលនៃការអភិវឌ្ឍគំរោងឆ្នាំចំរុះអាចមានការយឺតយ៉ាវ។ ដូចនេះ ជាមួយនឹងការគាំទ្រទ្រង់ទ្រាយតូចរបស់អង្គការអភិរក្សសត្វព្រៃ (WCS) ដែលជាចំនុចតូចមួយនៃការផ្តល់អោយអ្នកអភិរក្សថ្នាក់ជាតិ និងអន្តរជាតិធ្វើការកំនត់រកវិធីជួយថែរក្សាបន្ទាយសត្វ។ ប្រាំឆ្នាំក្រោយមក ព្រែកទាល់បច្ចុប្បន្នមានមោទនភាពក្នុងការក្លាយជាទីតាំងដែលមានសារៈសំខាន់ជាងគេប្រចាំតំបន់សំរាប់សត្វស្លាបទឹកធំៗ ជាមួយនឹងការស្តារឡើងវិញនូវជិរកប្រភេទ–សត្វដែលកំពុងរងការគំរាមកំហែងជាសាកល។ ការកត់សំគាល់ជាងនេះទៅទៀតនោះ គឺថាភាពជាក់ស្តែងព្រែកទាល់ស្ថិតនៅតំបន់ដែលមានការថយចុះ និងការផុតពូជដ៏លើសលប់ (dominant trends)។




**តារាង១.** បង្ហាញពីចំនួនកើនឡើងនៃសត្វស្មោញជាងបួនឆ្នាំនេះ។ ព្រែកទាល់បច្ចុប្បន្នជាបន្ទាយសត្វដ៏ធំបំផុតនៅលើពិភពលោក។



with the cooperation of the Ministry of Environment and the Fishing Lot, WCS started supporting the project using just a few thousand dollars of its core funds. With a commitment to working at site-level and a realisation that local problems needed local solutions, they began to work with the very people threatening the survival of the colonies: the fishing communities. A carefully balanced approach of carrot (employment and community revenue generation) and stick (law enforcement) began to shift people's perception of the birds from being a short-term meal to a long-term livelihood option.

By any measure, the project has had a positive impact on local livelihoods. First let's take the small scale. Over thirty ex-egg collectors and their families (>120 people) have consistently benefited through permanent employment in the conservation project. These are the kind of figures that are often dismissed by development specialists as being insignificantly small in number and unsustainable. However, five years down the line (longer than many development projects) these families are still employed and now have resources and security to be able to invest in diversifying their livelihood options, independent of a project, moneylender or donor agency. On a broader scale, the protection of the birds has also meant the prevention of a host of other illegal and unsustainable practices such as timber-collection and destructive fishing practices. It is interesting to note that, over the last four years, the number of local fishermen coming to fish at the edges of Prek Toal has increased. There may be more than one reason for this, not least the failure of other management prescriptions elsewhere on the lake, but if you ask them why they're here, the response tends to be 'because there are more fish'. Far from keeping fish populations down, colonial waterbirds help stimulate breeding and increase fertility of the water, while sensible conservation measures also protect spawning grounds, thus making significant contributions to local economies.

The project success raises interesting questions. What does it say about the current management strategies active on the lake that the one wildlife success story (and one of the few livelihood success stories) is situated in a Fishing Lot? Is the debate over Fishing Lots vs. Community Fisheries vs. Protected Areas missing the point? After all we have all three at Prek Toal.

Over thirty ex-egg collectors and their families (>120 people) have consistently benefited through permanent employment in the conservation project.

Clearly, the Prek Toal Conservation Project appears to provide a strong argument for practical negotiations between those involved with Fishing Lots, conservation and communities. The project proves that conservation can work, even in the most challenging of environments. It also shows that conservation is a genuine development option for some sites, and that thoughtful conservation can lead to sound livelihood alternatives.

Find out more about WCS on page 19

# WATER SNAKE TRADE

Water snake trade around the Tonle Sap Lake has escalated to a phenomenal scale. Monitoring programs carried out over the last two years have shown that upwards of four million snakes are hunted annually, making this the largest exploitation of any snake community in the world.

BY SHARON E. BROOKS, EDWARD H. ALLISON, JOHN D. REYNOLDS, TOUCH BUNTHANG, PROKROTEY KHOY



▲ Snakes being traded in Kampong Chhnang in the South of the Tonle Sap Lake

There are a number of different markets for the snakes of Tonle Sap Lake. The most significant is a local trade where snakes are used as animal feed to supply the numerous crocodile farms in and around the lake. Massive growth in the crocodile farm industry in Cambodia has taken place over the last twenty years (Jelden et al. 2005), placing enormous pressure on the lake's resources. While fish is still the major resource available, trade in the other wildlife of the lake, particularly snakes, has increased dramatically. In times of fish scarcity fishers living on the lake change their strategy to 'fish' water snakes from the lake using gill nets. Eight species are caught fairly regularly, of which five belong to the sub-family Homalopsinae, the Southeast Asian group of water snakes. This has resulted in a high availability of water snakes in local markets that in turn has caused a rise in human consumption of the snakes, and large quantities are now being transported from Tonle Sap Lake to urban centres around Cambodia. They have become a popular snack food, commonly served either fried or dried, and often accompanied with the local palm wine.

There are also international markets for the snakes of Tonle Sap (Bonheur & Lane 2002), both in the form of skins that are used for fashion products, as well as live animals that are used for human consumption, often in expensive restaurants. Although this is small in comparison to the local trade for crocodile food, representing less than 5 % of the number of individuals being sold, the impact on these higher value species is significant. The species being targeted are primarily the Bocourt's water snake (*Enhydris bocourti*) and the puff faced water snake (*Homalopsis buccata*) although pythons (*Python molurus*), and cobras (*Naja Kaouthia* and *N. siamensis*) are also traded occasionally.

Massive declines in the numbers of all species of snakes that are traded are being reported by both snake hunters and traders indicating that these activities are unsustainable and could lead to a loss of snake diversity and abundance within Tonle Sap. One of the species that is regularly caught, the Tonle Sap water snake (*Enhydris longicauda*), is endemic to the Tonle Sap Lake and River (Saint Girons 1972) and therefore is of




Table 1. The seasonal nature of snake trade based on the quantity landed at Chong Khneas port, Siem Reap.

global interest and concern. Due to differences in the biology and value of the species involved some are fairing far worse than others. The Bocourt's water snake and the Puff-faced water snake occur both incidentally in the crocodile food trade and are targeted for the skin and live trade where large females are sought. Unfortunately, those are also the most important for the continuation of their populations. This combination of exploitative pressure appears to be having devastating consequences for these two species, which have been highlighted by local villagers as having declined the most out of all the water snake species. In particular the Bocourt's water snake, the most valuable for its meat and skin (Stuart et al. 2000), is now a rarity within the lake.

The people living on the lake in floating communities have become increasingly dependent upon the snakes as a source of income as a result of declining fish catches. Possibly tens of thousands of people are engaging in snake hunting and for many this is a crucial part of their seasonal livelihood strategies. Efforts to protect the snake populations therefore need to be sensitive to the needs of some of the poorest people in Cambodia. For certain months of the year, between June and September, the capture of snakes to supply the crocodile farm industry is a critical and reliable source of

▼ Snake meat drying ready to be packed and sold as a local snack food.





▲ A Captive Siamese crocodile feeding on the endemic Tonle Sap water snake (*Enhydris longicauda*).

income for these people. However the capture of large snakes for the skin and live trade is more opportunistic. Due to the increasing difficulty of finding these high value species as they become rarer, this activity is an unreliable and therefore less important source of income. The costs associated with this activity are however low, as it can be carried out concurrently with other fishing activities, and therefore while the price is high there is sufficient incentive for hunting to continue.

The snakes of Tonle Sap are a prominent part of the ecosystem, providing food for large water birds (Tingay & Nicoll 2006) and undoubtedly for other predatory species including the wild crocodile (Daltry et al. 2003). Along with much of the other wildlife of Tonle Sap, the snakes are associated with the forest habitat surrounding the lake. Their habitat is therefore under continuing threat from conversion to agricultural land and dry-season forest fires (Bonheur & Lane 2002) and the snakes themselves face additional pressure from illegal practices occurring in the floodplain such as stream and pond pumping and electro fishing. Protection of this unique and threatened community of snakes therefore requires a multi-faceted approach to tackle the range of threats they are facing. Protection of the inundated forest and the prevention of illegal and destructive practices would secure their refuges, while harvests could be made more sustainable through measures such as closed hunting seasons to protect the breeding seasons of snakes, and further enforcement to prevent the capture and sale of the large individuals.

## References


Bonheur, N., and B. D. Lane. 2002. Natural resources management for human security in Cambodia's Tonle Sap Biosphere Reserve. Environmental Science and Policy 5:33-41.

Daltry, J., D. Chheang, P. Em, M. Poueng, H. Sam, P. Sorn, T. Tan, and B. K. Simpson. 2003. Status of the Siamese Crocodile in the Central Cardamom Mountains, Southwest Cambodia. FFI International Cambodia Program and Department of Forestry and Wildlife, Phnom Penh.

Jelden, D., C. Manolis, C. H. Giam, J. Thomson, and A. Lopez. 2005. Summary report of the IUCN-SSC Crocodile Specialist Group Review Mission to Cambodia. IUCN-SSC.

Saint Girons, H. 1972. Les Serpents du Cambodge. Page 170pp. Mémoires du Muséum National d'Histiore Naturelle, Paris, France.

Stuart, B. L., J. Smith, K. Davey, P. Din, and S. G. Platt. 2000. Homalopsine Watersnakes; The Harvest and Trade from Tonle Sap, Cambodia. TRAFFIC 18:115-124.

Tingay, R. E., and M. A. C. Nicoll. 2006. Asian Fishing Eagle Project: 2005 Pilot Study Report. Unpublished Report. Natural Research, Banchory, Scotland.


## Acknowledgements


We would like to thank all those who have contributed to this work, in particular the members of the research team, namely Chhey Sem, Van Sambor, Kranh Veasna, Seu pich, Lay Leng, Vanny and Chea Chanbora whose hard work and dedication has led to the success of this project. We would also like to thank those at WCS Cambodia (Heng Savannara, Long Kheng, Sun Visal and Joe Walston ) and the Sam Veasna Centre for Wildlife Conservation (Kristin Davies, Frederic Goes and Yok Pathomrath) for all their support throughout.

# PROJECTS

A wide range of natural resource managment activities are undertaken in the Tonle Sap Lake area. This section provides information about what is going on around the lake, focussing in this first issue on the common policy framework, environmental education and community fisheries.

## » TSBR COMMON POLICY FRAMEWORK AND COORDINATION MECHANISM

BY TIMOTHY WHITINGTON AND AM NORIN

Common policies proposed by the Tonle Sap Biosphere Reserve (TSBR) Secretariat provide the basis for integration of TSEMP project components and a consensus-based approach toward management of the Lake's assets. These common policies (common in the sense of shared in common by stakeholders) differ among themselves in what is expected from government agencies and civil society. An individual policy may invoke response from the Department of Fisheries, or the Ministry of Environment (two key agencies at which these policies are aimed); however other agencies of government may be affected only marginally. In general, departments under the Ministry of Agriculture, Forests and Fisheries, and other ministries (MLMUPC, MRD and MOI for example) will need to compromise on individual sector objectives, and in return will benefit, in respect to common policies. Active participation of provincial governments, often the chief custodians of existing resources, and central government counterparts at the provincial level, is important. With decentralization, district governments and commune councils also play important roles. In fact a complex array of compromises and benefits will need to be worked out in practice, over time.

### Role of the TSBR Secretariat

The role of the TSBR Secretariat, enshrined in the Royal Decree establishing the TSBR, is to facilitate the process of coordination, or mutual compromise and benefit. Common policies proposed by the Secretariat apply to the TSBR, and are not the Secretariat's policies in any sense; instead the Secretariat is a stakeholder with the unique position of coordinating among all stakeholders within the TSBR. The proposed common policies are far from being accepted, much less put into practice; in their present state they provide a sounding board for consensus building. The TSEMP policy component also proposes a coordination mechanism and interagency institutional structure through which common policies can be debated and implementation sequences developed.

The 34 common policies are addressing resource management issues with the principal goal of sustainable management of the Tonle Sap resource base.



◀ Commune chief of Kampong Ko Village in Kampong Thom province is welcoming the Policy and Strategy Networking Group of the TSBR Secretariat.

### The Common Policy Proposal

A Draft TSBR Common Policy Framework and Coordination Mechanism is available at the Secretariat's website (www.tsbr-ed.org). There are 34 common policies addressing specific resource management issues in three categories: conservation, sustainable development and research. These categories conform to the objectives for the TSBR established under the Royal Decree. Common policies extend the objectives of the Royal Decree by proposing how specific resources will be utilized and maintained. Because of the need for addressing specific resource issues, common policies exhibit some sector bias; however each and every common policy confronts two or more agencies in resolving management priorities. Benefits accrue to third parties who may not be directly involved in debate over the resource management issue. The principal benefit involves long term sustainable management of the Tonle Sap resource base.

### Beginning Efforts to Forge Common Policy

The TSEMP has organized numerous forums for presentation of the common policy framework, and indeed common policies are found implicit in the TSEMP project design. Nevertheless the most significant means for resolving viewpoints

# PROJECTS

...continued from page 7

Common Policy for the TSBR holds that "fishing lots may be significantly reduced or abolished in the core areas," "boundaries will be demarcated for fish sanctuaries in the TSBR," "zoning agreements . . . for protected areas [and] fish sanctuaries. . . . will be enforced [by] commune councils and provincial authorities", and the Secretariat advocates "flooded forest protection through zoning and land use policy." Concerning sustainable development, the Draft Common Policy asserts that "social land concessions will be used to support neglected stakeholders and vulnerable groups," "private developments . . . will avoid significant environmental impact and provide maximum benefit to local communities," and "land use and resource allocation plans within commune boundaries will be prepared." The viewpoint proffered here is that correct approaches should be followed and tools utilized to support good governance, defined here as "open, transparent communication and mutual consent regarding the means for natural resource utilization, which is expected to lead to intensive engagement of common citizens in decision making and action."



▲ Timothy Whitington and Am Norin are interviewing villagers from the floating village Peam Bang in Kampong Chhnang province.

The workshop was attended by provincial government and private sector stakeholders, including developers of dry season rice cultivation areas. Department of Fisheries staff recognized the threat to fish breeding grounds, and the Department of Water Resources and Meteorology acknowledged the threat to biodiversity and the need to study the problem. Department of Land Use Planning held out faith in the Down Area Paddy Field Allocation Committee to withhold licenses when there were negative environmental effects, or when flooded forests would be cleared, but came out against any move to zone conservation areas. Its representative asserted that the agency does not decide about concessions, or whether local authorities had rights to management of state owned land, but in any case it cannot stop granting license for dry season rice, for to do so might be to overstep its authority. There was extensive discussion on the course of action. The Secretariat advocated that the previously mentioned Allocation Committee be transformed into a Provincial Management Working Group , yet this motion was not acted on. Perhaps the group had decided not to acknowledge that land conversion was conceivably a factor harming the environment and local livelihoods.



▲ Villagers from Masa Krong Village gather, waiting to be interviewed about land use issues.

## Conclusion

We do not know how the effort will culminate to provide community-managed areas for preservation of Bengal Florican habitat, or how the larger issue will be resolved of land use zoning for sustaining multiple natural and community beneficial uses. The Secretariat, in its role as stakeholder and coordinator of common policies, will continue to pursue these issues. For the first time, the Secretariat made known its intention to moderate use of land in the TSBR through investigation of issues unfolding in the present time. «

### References

Evans, T. et. al.; Farming and its impact on flooded grasslands around the Tonle Sap lake: A survey in the Kruos Kraom area of Kampong Thom; WCS Cambodia Program; June 2005.

ADB; LOAN 1939–CAM; Aide-Mémoire of the Loan Review Mission for the Tonle Sap Environmental Management Project; 3 May 2006.



# » TONLE SAP ENVIRONMENTAL MANAGEMENT PROJECT

BY NEOU BONHEUR, DEPUTY PERMANENT SECRETARY, TONLE SAP BIOSPHERE RESERVE SECRETARIAT

